## ៨. សន្និដ្ឋាន

យោងលើលទ្ធផលនៃវាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាននិងសង្គម នៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ច ដែលស្នើសុំដោយក្រុមហ៊ុន **អេចអិលអេច អេគ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី** រួចមកក្រុមការងារ បានធ្វើការ សន្និដ្ឋានដូចខាងក្រោមៈ

**២៤០.** ជាទូទៅប្រភេទដីនៅតំបន់សម្បទាន ជាប្រភេទដីខ្សាច់ក្រម៉ៅ និងប្រផេះនៅតំបន់ជិតមាត់ទឹកនិងបាតអូរ ដីល្បាយខ្សាច់ មានថ្មផុសដោយកន្លែង ជាពិសេស តាមដងអូរ ដីឥដ្ឋក្រម៉ៅដោយកន្លែងដែលជាប្រភេទដីមានជីជាតិមធ្យមសំរាប់ដំណាំកសិ-ឧស្សាហកម្ម។ ដីនៅតាមប្រភេទព្រៃល្បោះជាដីល្បាយខ្សាច់ សង្កេតឃើញមាន ភ្លើងឆេះព្រៃក្នុងដីព្រៃល្បោះ ព្រោះរចនាសម្ព័ន្ធថ្នាក់ក្រោមជាប្រភេទស្មៅ ស្មៅព្រិច និងកូនឈើតូចៗ។ ក្រុមការងារបានសង្កេតឃើញថា ក្នុងតំបន់ដី សម្បទាននេះមានឈើពាណិជ្ជកម្មនៅសេសសល់តិចតួចណាស់។

**២៤១.** នៅតំបន់ដីសម្បទាននេះមិនសូវសម្បូរណ៍ប្រភពទឹកស្រទាប់លើច្រើនទេ។ ប្រជាជននៅតំបន់នោះបានជីកអណ្តូងសំរាប់ស្តុកទឹកប្រើប្រាស់នៅរដូវប្រាំងក្បែរភូមិនិងនៅក្នុងភូមិ។ តាមការពិនិត្យជាក់ស្តែងលើទីវាលបានសង្កេតឃើញថាអ្នកភូមិនៅតំបន់នោះប្រើប្រាស់ទឹកក្រោមដីដោយប្រើអណ្តូងស្នប់ កន្លែងខ្លះទៀតបានប្រើប្រាស់ទឹកស្រះ។ ប៉ុន្តែតាមរយៈការពិនិត្យលើផែនទីប្រើប្រាស់ដី និងគំរបព្រៃ បង្ហាញថា មានប្រព័ន្ធអូរ សំខាន់មាន ០៤ខ្សែប៉ុណ្ណោះនៅរដូវវស្សា គឺអូរកោដ្ឋី អូរសំរោង អូរព្រះធាតុនិងស្ទឹងគ្រាំងក្រាង។ ដោយហេតុ ថាដីសម្បទាននេះស្ថិតនៅឆ្ងាយពីតំបន់ឧស្សាហកម្ម ដូច្នេះ គុណភាពទឹកស្រទាប់លើក្នុងតំបន់នេះមិនទាន់ ទទួលរងការបំពុលដោយជាតិគីមីនៅឡើយទេ ហើយប្រជាជននៅក្នុងតំបន់នោះបានប្រើប្រាស់ទឹកពីប្រភព ទាំងនោះទៀតផងនៅរដូវវស្សាដើម្បីធ្វើស្រែ និងប្រើប្រាស់។

**២៤២.** ដីសម្បទានតំបន់នេះមានព្រៃពីរប្រភេទគឺៈ ព្រៃល្បោះ និងព្រៃពាក់កណ្តាលស្រោង។ រុក្ខជាតិថ្នាក់ក្រោមមានកូនឈើតូចៗ ស្មៅ និងស្មៅព្រិច ហើយមានសភាពស្ងួត ខ្លាំងនៅរដូវប្រាំង និងមានភ្លើងឆេះ។

**២៤៣.** នៅក្នុងព្រៃល្បោះ ដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតធំជាង ៥០សម ពុំសង្កេតឃើញមានវត្តមាននៅតំបន់នេះទេ។ ចំពោះដង់ស៊ីតេ ឈើដែលមានអង្កត់ផ្ចិតពី ៣០-៤៩សម មានពី ៦-៣២ដើមក្នុង១ហិកតា ដោយគិតជាមធ្យមមាន ៧ដើមក្នុង ១ហិកតា។ ដូច្នេះក្នុងដីព្រៃល្បោះ ៨៨៥៤ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ៣០-៤៩សម មានចំនួន ៦១៩៧៨ ដើម។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី ១០-២៩សម មានពី ១២-៤២ដើមក្នុង១ហិកតា ដោយគិតជា មធ្យមមាន ២៥ដើមក្នុង១ហិកតា។ ដូច្នេះក្នុងដីព្រៃល្បោះ ៨៨៥៤ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ១០-២៩សម មានចំនួន ២២១៣៥០ដើម។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិត

Draft

ពី ៥-៩សម មានពី ២៥-៧៦ដើមក្នុង ១ហិកតា ដោយគិតជាមធ្យមមាន ៤៨ដើមក្នុង១ហិកតា។ ដូច្នេះ ក្នុងដីព្រៃល្បោះ ៨៨៥៤ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ៥-៩សម មានចំនួន ៤២៤៩៩២ដើម។ ស្ថានភាពគំរបព្រៃក្នុងតំបន់នេះជាមធ្យមមាន តែ ១៨ភាគរយ នៃផ្ទៃដីបានសិក្សាសរុបតែប៉ុណ្ណោះ។

**២៤៤.** នៅក្នុងព្រៃពាក់កណ្តាលស្រោង ដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតធំជាង ៥០សម ពុំសង្កេតឃើញមានវត្តមាននៅតំបន់នេះទេ។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី ៣០-៤៩សម មានពី ១២-១៨ដើម ក្នុង ១ហិកតា ដោយគិតជាមធ្យមមាន ១៥ដើមក្នុង១ហិកតា។ ដូច្នេះក្នុងដីព្រៃពាក់កណ្តាលស្រោង ៣៣១,៣ ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ៣០-៤៩សម មានចំនួន ៤៩៧០ដើម។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី ១០-២៩សម មានពី ១៩-២៤ដើមក្នុង១ហិកតា ដោយគិតជាមធ្យមមាន ២២ដើមក្នុង១ហិកតា។ ដូច្នេះក្នុងដីព្រៃពាក់កណ្តាលស្រោង ៣៣១,៣ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ១០-២៩សម មានចំនួន ៧២៨៩ដើម។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី ៥-៩សម មានពី ៣៥-៤៥ដើមក្នុង១ហិកតា ដោយគិតជាមធ្យមមាន ៤០ដើមក្នុង១ហិកតា។ ដូច្នេះក្នុងដីព្រៃពាក់កណ្តាលស្រោង ៣៣១,៣ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ៥-៩ សម មានចំនួន ១៣២៥២ដើម។ ស្ថានភាពគំរបព្រៃក្នុងតំបន់នេះជាមធ្យមមានតែ ៣៤ភាគរយ នៃផ្ទៃដីបានសិក្សាសរុបតែប៉ុណ្ណោះ។

**២៤៥.** នៅក្នុងព្រៃល្បោះ ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ៤០-៤៩ស.ម មានពី ៣៩៦២-១៣៨៦៧គ.ក្រ ក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ៣០១៤,៥៧គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដីព្រៃល្បោះចំនួន ៨៨៥៤ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ៤០-៤៩ស.ម មានសរុបចំនួន ២៦៦៩១០០២,៧៨គ.ក្រ។ ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ៣០-៣៩ស.ម មានពី ៥៥៨០-៣០១៣២គ.ក្រ ក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ៤៨៥២,១៧គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដីព្រៃល្បោះចំនួន ៨៨៥៤ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ៣០-៣៩ស.ម មានសរុបចំនួន ៤២៩៦១១១៣,១៨គ.ក្រ។ ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ២០-២៩ស.ម មានពី ៩៩៨-៥៤៨៩គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ៣២៥៤,៣៥គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដីព្រៃល្បោះចំនួន ៨៨៥៤ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ២០-២៩ស.ម មានសរុបចំនួន ២៨៨១៤០១៤,៩គ.ក្រ។ ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ១០-១៩ស.ម មានពី ៩១០-៤១៦០គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ២២៧៧,៨៣គ.ក្រ ក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដី ព្រៃល្បោះចំនួន ៨៨៥៤ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតពី ១០-១៩ស.ម មានសរុបចំនួន ២០១៦៧៩០៦,៨២គ.ក្រ។

**២៤៦.** នៅក្នុងព្រៃពាក់កណ្តាលស្រោងជីវម៉ាស់ឈើ ដែលមានអង្កត់ផ្ចិតចាប់ពី ៤០-៤៩ស.ម មានពី ៧៩២៤ -១៥៨៤៨គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ១១៨៨៦គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដី

ព្រៃពាក់កណ្តាលស្រោងចំនួន ៣៣១,៣ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៤០-៤៩ស.ម មានសរុបចំនួន ៣៩៣៧៨៣១,៨គ.ក្រ ។ ជីវម៉ាស់ឈើ ដែលមានអង្កត់ផ្ចិតចាប់ពី ៣០-៣៩ស.ម មានពី ៨៩២៨-១១១៦០គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យម មាន ១០០៤៤គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដីព្រៃពាក់កណ្តាលស្រោងចំនួន ៣៣១,៣ហិកតា ជីវម៉ាស់ ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៣០-៣៩ស.ម មានសរុបចំនួន ៣៣២៧៥៧៧,២គ.ក្រ ។ ជីវម៉ាស់ឈើដែល មានអង្កត់ផ្ចិតចាប់ ពី ២០-២៩ស.ម មានពី ៣៤៩៣-៤៩៩០គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យមមាន ៤២៤២គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើផ្ទៃដីព្រៃពាក់កណ្តាលស្រោងចំនួន ៣៣១,៣ហិកតា ជីវម៉ាស់ឈើ ដែលមានអង្កត់ផ្ចិតចាប់ពី ២០-២៩ស.ម មានសរុបចំនួន ១៤០៥៣៧៤,៦គ.ក្រ ។ ជីវម៉ាស់ឈើដែលមាន អង្កត់ផ្ចិតចាប់ពី ១០-១៩ស.ម មានពី ១៥៦០-១៨២០គ.ក្រក្នុងមួយហិកតា ដោយគិតជាមធ្យមមាន១៦៩០គ.ក្រក្នុងមួយហិកតា ដូច្នេះនៅលើ ផ្ទៃដីព្រៃពាក់កណ្តាលស្រោងចំនួន៣៣១,៣ហិកតា ជីវម៉ាស់ឈើដែលមានអង្កត់ផ្ចិតចាប់ពី ១០-១៩ស.ម មានសរុបចំនួន ៥៥៩៨៩៧គ.ក្រ ។

**២៤៧.** នៅក្នុងព្រៃល្បោះ ៨៨៥៤ហិកតា កំណើនជីវម៉ាស់របស់ឈើដែលមានអង្កត់ផ្ចិតធំជាង ១០ស.ម ក្នុងដីសម្បទាននេះ មានចាប់ពី ២៨៤៧,២២-៣១៣០,៥៥មេកាក្រាម ក្នុងរយៈ៥ឆ្នាំដំបូង (ឆ្នាំទី១-ឆ្នាំទី៥) ចាប់ពី ៣២០៥,៦៨-៣៥២៤,៦៨មេកាក្រាមក្នុងរយៈ៥ឆ្នាំបន្ទាប់ (ឆ្នាំទី៦-ឆ្នាំទី១០) និងចាប់ពី ៣៦០៩,២៧-៣៩៦៨,៤៤មេកាក្រាម ក្នុងរយៈ១៥ឆ្នាំក្រោយ ។ កំណើនជីវម៉ាស់សរុបគិតចាប់ពីឆ្នាំទី១ ដល់ឆ្នាំទី១៥ ស្មើនឹង ៥០៦៨៦,០៩មេកាក្រាម ។

**២៤៨.** នៅក្នុងព្រៃពាក់កណ្តាលស្រោង ៣៣១,៣ហិកតា កំណើនជីវម៉ាស់របស់ឈើដែលមានអង្កត់ផ្ចិតធំជាង ១០ស.ម ក្នុងដីសម្បទាននេះមានចាប់ពី ១៩៣,៨៤-២១០,៦៤មេកាក្រាម ក្នុងរយៈ៥ឆ្នាំដំបូង (ពីឆ្នាំទី១ ដល់៥) ចាប់ពី ២១៥,០៧-២៣៣,៧១មេកាក្រាម ក្នុងរយៈ៥ឆ្នាំបន្ទាប់ (ពីឆ្នាំទី៦ដល់១០) និងចាប់ពី ២៣៨,៦២-២៥៩,៨០ មេកាក្រាម ក្នុងរយៈ១៥ឆ្នាំក្រោយ ។ កំណើនជីវម៉ាស់សរុបគិតចាប់ពីឆ្នាំទី ១ ដល់ឆ្នាំ ១៥ ស្មើនឹង ៣៣៧៦,៤៩មេកាក្រាម ។

**២៤៩.** តាមរយៈការសិក្សាលំអិតទៅលើរូបភាព Photo-Index-F និងរូបភាព Eye_View3 និង4 ទៅលើស្ថានភាពនៃការប្រើប្រាស់ដីក្នុងតំបន់ដែនសម្បទានបង្ហាញថា មានដីស្រែចំការរបស់ប្រជាជនមូលដ្ឋានដោយកន្លែងដែលនៅផ្នែកខាងត្បូងនៃដែនដីដែលស្នើសុំ ។ តាមការដែលជួបសន្ទនា ពិភាក្សាពិគ្រោះជាមួយប្រជាពលរដ្ឋនៅទីនោះបានបញ្ជាក់អោយដឹងថា នៅក្នុងតំបន់ដូចបានរៀបរាប់នេះពិតជាមានដីស្រែចំការរបស់ពួកគាត់មែនគឺមានទាំងនៅផ្នែកខាងត្បូង និងខាងជើងផងដែរ ។ ក្រៅពីការសិក្សាទៅលើស្ថានភាពនៃការប្រើប្រាស់ដីក្រុមការងារក៏បានចាប់អារម្មណ៍ទៅលើបញ្ហាការកាប់ព្រៃឈើយ៉ាងអាណាធិប្បតេយ្យ ដែលដឹកចេញតាមផ្លូវរទេះដែលមាននៅក្នុងដែនដីស្នើសុំនេះដែរ ។

Draft

**២៥០.** តាមរយៈការសិក្សាអំពីស្ថានភាពប្រើប្រាស់ដី (តាមរយៈការជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំស្រុកឱរ៉ាល់) បានអោយដឹងថា ការផ្តល់ដីសម្បទាននៅក្នុងតំបន់នេះ បានបណ្តាលអោយប៉ះពាល់ដល់លទ្ធភាពប្រើប្រាស់ផល-អនុផលព្រៃឈើ របស់ប្រជាជននៅក្នុងឃុំសង្កែសាទប និងឃុំត្រពាំងជោ ស្រុកឱរ៉ាល់។ ពួកគាត់ (អ្នកភូមិនៅក្នុង ឃុំ) មានដីស្រែ-ចំការ កន្លែងទីសក្ការៈ និងព្រៃសហគមន៏ដែលស្ថិតក្នុងទីតាំងដែលក្រុមហ៊ុនបានស្នើសុំ។

**២៥១.** ក្នុងដំណើរអង្កេត និងសំភាសន៏ដល់ប្រជាជនដែលរស់នៅក្បែរទីនោះបានអោយដឹងថា នៅក្នុងដីសម្បទាននោះមានសត្វឈ្លូស ជ្រូកព្រៃ ក្រចាំង សំពោច កំប្រុក មាន់ព្រៃ កង្ហែន ពស់ អណ្តើក ។ល។ ប៉ុន្តែគ្មានវត្តមានសត្វចតុប្បាទធំៗដូចជា ខ្ទីង ប្រើស និងពពួកមំសាសីធំៗ តួយ៉ាងខ្លា ខ្លារខិនទេ។ ចំពោះប្រភេទសត្វបក្សីនៅក្នុងតំបន់ដីសម្បទាននេះពុំមានសត្វអ្វីគួរអោយកត់សំគាល់ទេក្រៅពី ទទារ រលក ត្រសេះ ក្រដេវិច ជាដើម។

**២៥២.** ជីវភាពរស់នៅរបស់ប្រជាជនរស់នៅក្នុងភូមិទាំងមូលដែលជាប់ពាក់ព័ន្ធនឹងដីព្រៃសម្បទាន គឺអាស្រ័យទៅលើការធ្វើស្រែ និងចំការ ដែលពួកគាត់ចាត់ទុកថា ជាមុខរបរសំខាន់របស់ពួកគាត់។ ទន្ទឹមនឹងនេះដែរដើម្បីបង្គ្រប់ភាពខ្វះខាតជីវភាពក្នុងគ្រួសារ ពួកគាត់បានកាប់ទន្រ្ទានដីព្រៃសំរាប់ធ្វើចំការដាំដំណាំផ្សេងៗ ដូចជាៈ ស្រូវ ឪឡឹក ដំឡូងជ្វា អំពៅជាដើម។ លើសពីនេះទៅទៀត ពួកគាត់បានចូលព្រៃដើម្បីកាប់ឈើមូល កូនឈើ ឈើក្រាក់ អុស រកវល្លិ៍ វាយផ្តៅ រកទំពាំង កាប់ឬស្សី ដងជ័រទឹក និងបរបាញ់សត្វ។

**២៥៣.** ប្រភពចំណូលសំខាន់របស់ពួកគាត់ គឺអាស្រ័យលើមុខរបរធ្វើស្រែចំការ និងកាប់អុសម៉ែត្រ និងដុតធ្យូង (ដែលមួយខែៗ គ្រួសារនិមួយៗអាចរក ចំណូលបានចន្លោះពី ២០០០០០-៦០០០០០រៀល គ្រួសារនិមួយៗមានឡធ្យូងពី១-៥ឡ ហើយឡនិមួយៗ ប្រើប្រាស់ឈើអុសចាប់ ពី៥-១០រទេះ(គោយន្ត)។ ចំណែកការធ្វើស្រែចំការវិញគឺសំរាប់តែទុកហូបនៅក្នុងគ្រួសារ តែប៉ុណ្ណោះ ដែលក្នុង មួយហិកតាអាចទទួលបានទិន្នផល១-២,៥តោន ហើយស្រូវមួយគីឡូក្រាមលក់បានតំលៃ ៨០០-១៥០០រៀល) ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារជាក់ស្តែងប្រជាពលរដ្ឋមានលទ្ធភាពអាចចិញ្ចឹមគោ ប្រមាណជា៨០%នៃចំនួន ប្រជាជនសរុបតាមភូមិនិមួយៗក្នុងនោះចំនួន៩០%បានចិញ្ចឹមគោពី៣-៥ក្បាល និង ប្រមាជា១០%បានចិញ្ចឹម គោពី១០-២០ក្បាល។ ជាទូទៅការចិញ្ចឹមគោរបស់ពួកគាត់គឺ មិន ត្រឹមតែសម្រាប់ ការប្រើប្រាស់ជាមធ្យោបាយ អូសទាញក្នុងការធ្វើស្រែចំការ និងចូលព្រៃដឹកឈើប៉ុណ្ណោះទេ ពួកគាត់ចិញ្ចឹមសំរាប់ លក់ដូរផងនិងទុកគ្រាន់ ដោះស្រាយនៅពេលមានគ្រោះអាសន្នអន់ក្រផង។ តែក៏មានគ្រួសារមួយចំនួនពុំមាន ស្បៀងអាហារហូបគ្រប់គ្រាន់ ដែលមានគ្រួសារខ្លះខ្វះខាតស្បៀងរហូតដល់ទៅ ២-៣ ខែឯណោះ។

Draft

**២៥៤.** សេដ្ឋកិច្ចក្នុងតំបន់មានលក្ខណៈជាសេដ្ឋកិច្ចជនបទ លើកលែងតែទីរួមខេត្តចេញ ដែលការប្រកបរបរមានទ្រង់ទ្រាយពាណិជ្ជកម្ម។ ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងសហគមន៍មានលក្ខណៈផ្សេងៗគ្នាអាស្រ័យទៅនឹងការប្រកបមុខរបររបស់គ្រួសារនិមួយៗ។ ការវាយតំលៃអំពីភាពក្រីក្របានបង្ហាញថា អត្រានៃភាពក្រីក្រនៅក្នុងខេត្តកំពង់ស្ពឺមានៈ ១៨,២០ភាគរយ (១០៥,៣៣៣នាក់) លើចំនួនប្រជាជនសរុប ៦៩០៩៦៣នាក់ ក្នុងនោះមាន ៦៤១៦៣០នាក់ ស្មើនឹង ៩៣ភាគរយរស់នៅជនបទ (ផែនទីភាពក្រីក្ររបស់កម្មវិធីស្បៀង អង្គការសហប្រជាជាតិឆ្នាំ២០០៥-២០០៦ និងប្រព័ន្ធទិន្នន័យសហគមន៍ឆ្នាំ២០០៤)។ ចំនួនអ្នកមិនចេះអក្សរនៅក្នុងខេត្តកំពង់ស្ពឺទាំងមូលមានចំនួន ៨២៨០៦នាក់។

**២៥៥.** ជាទូទៅលទ្ធភាពនៃការប្រើប្រាស់សេវាសាធារណៈមានៈ គមនាគមន៍ ការផ្គត់ផ្គង់ទឹកស្អាត អគ្គីសនី អប់រំ និងសុខាភិបាល នៅក្នុងស្រុកនេះស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ។ ការសិក្សាបាន បង្ហាញអោយឃើញថា អ្នកដែលរស់នៅតាមដងផ្លូវ ក៏ដូចជាប្រជាជនដែលរស់នៅតាមភូមិក្នុងស្រុកឱរ៉ាល់ ទាំងអស់ដែរ ពុំបានទទួលការផ្គត់ផ្គង់អគ្គិសនីជាមូលដ្ឋានទេ។ គ្រួសារភាគច្រើនប្រើអាគុយ និងមួយចំនួន ទៀតបានប្រើប្រាស់ចង្កៀងប្រេងកាតសំរាប់បំភ្លឺនៅពេលយប់។ រីឯប្រភពថាមពលសំខាន់សំរាប់ការចំអិន អាហាររបស់ពួកគាត់គឺអុស និងធ្យូង។

**២៥៦.** ការធ្វើដំណើរ និងដឹកជញ្ជូនភាគច្រើនគឺ ប្រើប្រាស់ផ្លូវលេខ៥២ (ទីប្រជុំជនស្រុកឧដុង-ស្រុកឱរ៉ាល់) និងផ្លូវលេខ៤៤ (ស្រុកច្បារមន-ស្រុកឱរ៉ាល់) និងផ្លូវលំតូចៗចេញពីភូមិមក (ទីប្រជុំជនភូមិដំបងវេញ- ឃុំត្រពាំងជោ)ដែលជាផ្លូវយ៉ាងសំខាន់ចូល ទៅក្នុងតំបន់ដីសម្បទាននេះ។ ចំពោះស្ថានភាពផ្លូវគមនាគមន៍ ក្នុងតំបន់នេះជាផ្លូវក្រាលគ្រួសក្រហម ប៉ុន្តែ បានទទួលរងនូវការខូចខាត ដោយកន្លែងដែលបណ្តាលពីការដឹកជញ្ជូនលើសកំណត់ជារឿយៗ។ នៅរដូវប្រាំងផ្លូវ មានសភាពហុយខ្លាំង ចំណែកនៅរដូវវស្សាវិញផ្លូវមានសភាពរអិល និងមានដក់ទឹកដោយកន្លែង ហើយពួកគាត់ប្រើប្រាស់កង់ ម៉ូតូ និងរថយន្តជាមធ្យោបាយធ្វើដំណើរ ឬដោយថ្មើរជើងនៅក្នុងតំបន់។

**២៥៧.** យោងលើភាពរឹងប៉ឹងនៃគំរោងវិនិយោគតាមរយៈការគណនាតំលៃបច្ចុប្បន្ន (Present Value)នៃលំហូរសាច់ប្រាក់រយៈពេល២០ឆ្នាំ ដោយកំណត់យកអត្រា (Discounted Rate) ស្មើនឹង ៨% ការគណនាតំលៃបច្ចុប្បន្នសុទ្ធ (Net Present Value or NPV) និងការគណនាអត្រាចំណូលវិនិយោគ ខាងក្នុង Internal Rate of Return (IRR)។ លទ្ធផលនៃការគណនាបានបង្ហាញថាៈ (១) Present Value មានតំលៃស្មើនឹង ២៦.៤៣៥.៣៤៦ ដុល្លាអាមេរិក នោះក្រុមហ៊ុនត្រូវការដើមទុនអាជីវកម្មសំរាប់ ០៩ឆ្នាំដំបូងគឺប្រមាណជាង ២៦.៤៣ លានដុល្លាអាមេរិក ប្រសិនបើអត្រា Discounted Rate មានតំលៃស្មើនឹង ០៨% (២) Net Present Value or NPV មានតំលៃស្មើនឹង ៣១.៤១៧.២០៩ លានដុល្លាអាមេរិក តំលៃ

Draft

បច្ចុប្បន្នសុទ្ធនៃ គំរោងនេះគឺជាចំនួនវិជ្ជមាន ដូច្នេះ ក្រុមហ៊ុនអាចសន្និដ្ឋានបានថា ការធ្វើអាជីវកម្មមានដំណើរការល្អអាចទទួល យកបាន (៣) ប្រសិនបើ IRR មាន តំលៃ ១៤% នោះក្រុមហ៊ុនអាចមានក្តីសង្ឃឹមច្រើនក្នុងការធ្វើអាជីវកម្មរបស់ខ្លួន ព្រោះ Internal Rate of Return មានទំហំធំរហូតដល់ ១៤ភាគរយ នៅពេលដែល Discounted Rate កំណត់ត្រឹម ០៨ភាគរយ (៤) រយៈពេលប្រមូល ទុនមកវិញ-Payback Period ក្នុងរង្វង់រយៈពេល ១៦ ឆ្នាំ ដោយក្រុមហ៊ុនអាចមានលទ្ធភាពទូទាត់សង និងប្រមូលបានមកវិញ នៅដើមទុនវិនិយោគ របស់គំរោងអាជីវកម្មនេះ និង (៥) ក្នុងនោះ សន្ទស្សន៍ នៃផលចំណេញ-Profitability Index or Benefit/Cost Ratio ក្នុងរយៈពេល២០ឆ្នាំដំបូងនេះត្រូវបាន គណនាឃើញប្រហែល ១.៣៦ មានន័យថា គំរោងវិនិយោគនេះអាចទទួលយកបាន ព្រោះសន្ទស្សន៍ផល ចំណេញធំជាង០១ ឬអាចនិយាយបានថា ១ដុល្លាអាមេរិក ដែលបានវិនិយោគនឹងអាចបង្កើនតំលៃបាន ០.៣៦ ដុល្លាអាមេរិក។

**២៥៨.** យោងលើស្ថានភាពធនធានរូបវន្ត ធនធានអេកូឡូស៊ី ធនធានសង្គមនិងសេដ្ឋកិច្ចរបស់ដីសម្បទានដូចដែលបានធ្វើការសន្និដ្ឋានខាងលើ យើងអាចធ្វើការវិនិច្ឆ័យបានថា ការប្រែក្លាយតំបន់ដីសម្បទានមួយដែលមានធនធានរេចរិល បែបនេះអោយទៅជាតំបន់កសិ-ឧស្សាហកម្មដោយការដាំដំណាំ ពោត និងដំណាំផ្សេងៗ។ ដោយឡែក គំរោងអភិវឌ្ឍន៍នេះ គឺជាការចូលរួមយ៉ាងសំខាន់មួយក្នុងការធ្វើអោយសម្រេចបាននូវគោលនយោបាយ របស់រាជរដ្ឋាភិបាលនៅក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតអោយមានកាលានុវត្តភាព ការងារ ជំរុញអោយមានចរន្តសេដ្ឋកិច្ច និងការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈនៅក្នុងសហគមន៍មូលដ្ឋានផងដែរ។

Draft

## ៩. អនុសាសន៍

យោងលើសេចក្តីសន្និដ្ឋានស្តីពីហេតុប៉ះពាល់បរិស្ថាននិងសង្គមនឹងដើម្បីធានាបានថា គំរោងអភិវឌ្ឍន៍ដំណាំកសិឧស្សាហកម្មរបស់ក្រុមហ៊ុន **អេចអិលអេច អេគ្រីខលឈើរ(ខេមបូឌា) ខូអិលធីឌី** ក្រុមការងារសូមផ្តល់នូវអនុសាសន៍ដូចខាងក្រោមៈ

**២៥៩.** នៅក្នុងដំណើរប្រតិបត្តិការគំរោង សាមីវិនិយោគគិន ត្រូវតែអនុវត្តផែនការគ្រប់គ្រងបរិស្ថានទៅតាមវិធានការណ៍នានាដូចមានកំណត់នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន ដូចបានពណ៌នានៅក្នុងតារាង ៦-១ និងតារាង៦-៣ នោះស្ថាប័នជំនាញ និងអាជ្ញាធរពាក់ព័ន្ធត្រូវតាមដានពិនិត្យនឹងវាយតំលៃទៅលើសកម្មភាពនៃការអភិវឌ្ឍន៍របស់វិនិយោគគិនជាប្រចាំ ទៅតាមកម្មវិធីដូចមាន កំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។

ភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩

**នាយក**

**ហត្ថលេខា និងត្រា**

Green Consultancy Firm

KINGDOM OF CAMBODIA

**បណ្ឌិត លី សុពណ៌-ធុនី**

ភ្នំពេញ ថ្ងៃទី 21 ខែ 12 ឆ្នាំ ២០០៩

**នាយកក្រុមហ៊ុន**

**ហត្ថលេខា និងត្រា**

HLH Agriculture (Cambodia) Co., Ltd.

ONG BEE HUAT

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

---

## កំណត់ហេតុកិច្ចប្រជុំពិភាក្សាលើបទបង្ហាញ

## ស្តីពី

## របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម លើគំរោងស្នើសុំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេច អិល អេច អាគ្រីខាល់ឆើ ខេមបូឌា ខូអិលធីឌី ស្ថិតនៅ ឃុំសង្កែសាទប និង ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ

Draft

ឆ្នាំពីរពាន់ប្រាំបួន ខែ វិច្ឆិកា ថ្ងៃទី ដប់ប្រាំមួយ កាលពីវេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅសាលប្រជុំសាលាខេត្តកំពង់ស្ពឺ មានបើកកិច្ចប្រជុំពិភាក្សានិងធ្វើបទបង្ហាញស្តីពីរបាយការណ៍វាយតំលៃ ហេតុប៉ះពាល់បរិស្ថាន និងសង្គម លើគំរោងស្នើសុំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន **អេចអិលអេច អេគ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី** ដែលមានទីតាំងភូមិសាស្ត្រស្ថិតនៅ ឃុំសង្កែសាទប និង ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ក្រោមអធិបតីភាព **ឯកឧត្តម កង ឃាង** អភិបាលខេត្ត កំពង់ស្ពឺ ។

**សមាសភាពអញ្ជើញចូលរួមក្នុងឱកាសនោះមាន:**

| | | |
|---|---|---|
| ១- | ឯកឧត្តម ទូច សារុន | អភិបាលរងខេត្តទទួលបន្ទុក |
| ២- | លោក វ៉ាន់ សុខា | អគ្គលេខាធិការរងសាលាខេត្ត |
| ៣- | លោក កង វណ្ណារ៉ូ | អគ្គលេខាធិការរងសាលាខេត្ត |
| ៤- | លោក សៅ សត្យា | នាយខុទ្ទកាល័យសាលាខេត្ត |
| ៥- | លោក ចាន់ សុគន្ធ | នាយខុទ្ទកាល័យសាលាខេត្ត |
| ៦- | លោក ហេង គួន | ប្រធានមន្ទីរបរិស្ថានខេត្ត |

| | | | |
|---|---|---|---|
| ៧- | លោក | យឹម ណន | តំណាងមន្ទីរកសិកម្មខេត្ត |
| ៨- | លោក | ឡាយ គីមហៀង | ប្រធានមន្ទីររៀបចំដែនដី |
| ៩- | លោក | ចែម សារីម | អភិបាលស្រុកឱរ៉ាល់ |
| ១០- | លោក | ចាន់ វណ្ណា | បុគ្គលិក Green Consultancy Group |
| ១១- | លោក | អ៊ុន ចាន់ណារ៉ូ | បុគ្គលិក Green Consultancy Group |
| ១២- | លោក | ទូច សាលីន | នាយរងខ័ណ្ឌរដ្ឋបាលព្រៃឈើ |
| ១៣- | លោក | ណែម ទីន | នាយខ័ណ្ឌរដ្ឋបាលព្រៃឈើ |
| ១៤- | លោក | ព្រំ សំអុន | អនុប្រធានមន្ទីរឧស្សហកម្ម |
| ១៥- | លោក | យ៉ង់ យារិទ្ធ | នាយសង្កាត់រដ្ឋបាលព្រៃឈើត្រពាំងជោ |
| ១៦- | លោក | ឯម សុខុម | នាយសង្កាត់រដ្ឋបាលព្រៃឈើតាសាល |

Draft

ជាកិច្ចចាប់ផ្តើមឯកឧត្តមគណៈអធិបតី បានថ្លែងកិច្ចស្វាគមន៍ចំពោះសមាជិកនៃអង្គពិធីព្រមទាំងប្រកាសបើកកិច្ចប្រជុំដែលមានខ្លឹមសារដូចខាងក្រោមៈ

**ឯកឧត្តម កង ហ៊ាង** អភិបាលខេត្តៈ ជាបឋមខ្ញុំសូមធ្វើការចាប់អារម្មណ៍ចំពោះការស្នើសុំ ដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន អេចអិលអេច អេហ្គ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី ហើយអ្វីដែលជាការយកចិត្តទុកដាក់ និងត្រូវធ្វើការផ្តោតអារម្មណ៍នោះ ទៅលើការងារ សំខាន់ចំនួន០៣គឺ(១) ធនធានៈ បញ្ហានេះគឺសំដៅទៅលើថា តើក្រុមហ៊ុនមានសមត្ថភាព និងធនធានគ្រប់គ្រាន់សំរាប់ យកមកធ្វើការអភិវឌ្ឍន៍លើទំហំដីដែលក្រុមហ៊ុនស្នើសុំនេះ ដែរឬទេ? (២) តើក្រុមហ៊ុនមានសម្ភារៈបច្ចេកទេស និង ធនធានមនុស្សដើម្បីធ្វើការអភិវឌ្ឍន៍លើទីតាំង និងទំហំដី ដែលក្រុមហ៊ុនស្នើសុំដែរឬទេ? និង(៣) ត្រូវផ្តោតអារម្មណ៍ ទៅលើទីតាំងដីដែលក្រុមហ៊ុនធ្វើការស្នើសុំនោះ តើមាន ជាន់និងក្រុមហ៊ុនណាខ្លះ? ចំពោះទឹកដីខេត្តកំពង់ស្ពឺនោះ មានផ្ទៃដីច្រើនណាស់ដែលត្រូវធ្វើការអភិវឌ្ឍន៍ ហើយកន្លងមក ឯកឧត្តមអភិបាលខេត្តបានធ្វើការអំពាវនាវទៅក្រុមហ៊ុនមួយចំនួន ដើម្បីមកធ្វើការបណ្តាក់ទុន និងអភិវឌ្ឍន៍នៅ ក្នុងទឹកដីខេត្តកំពង់ស្ពឺយើងនោះ ហើយក៏មានក្រុមហ៊ុនជាច្រើនមានការចាប់អារម្មណ៍ផងដែរ ។ ដូចនេះគំរោងស្នើសុំ ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន **អេចអិលអេច អេហ្គ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី** តើអាចនឹង មានការប៉ះពាល់អ្វីខ្លះ? បើតាមមតិរបស់ខ្ញុំឃើញថា មានការងារសំខាន់ៗចំនួន០៤ ដែលត្រូវលើកយកមកពិភាក្សានេះ គឺៈ

១- និយាយអំពីផលប៉ះពាល់បរិស្ថានៈ ជីវចំរុះ ព្រៃសហគមន៍ និងដែនជំរកសត្វជាដើម

២- អំពីធនធានព្រៃឈើៈ ព្រៃស្រោង ពាក់កណ្តាលស្រោង ពិសេសពាក់ព័ន្ធទៅនឹងគំរបព្រៃឈើ ជាដើម ។

៣-អំពីការប្រើប្រាស់ដីៈ ត្រូវធ្វើការបញ្ចៀសនូវការបន្សល់ទុកបញ្ហា ដែលធ្វើអោយមានការលំបាកក្នុងការដោះស្រាយពិសេសដីពាក់ព័ន្ធ និងប្រជាពលរដ្ឋ។ បច្ចុប្បន្នបញ្ហាដែលបានជួបប្រទះចំពោះមុខ គឺសុំឱ្យក្រុមការងារបានធ្វើការសិក្សាស្រាវជ្រាវអំពីភាពជាក់លាក់ ដើម្បីរកនូវដំណោះស្រាយមួយសមស្របទាំងក្រុមហ៊ុន ទាំងប្រជាពលរដ្ឋដែលជាបញ្ហាកន្លងមក នៅតំបន់របស់ខេត្តមួយចំនួន នៃប្រទេសកម្ពុជា។ ដោយសារតែគំរោងដីសម្បទានសេដ្ឋកិច្ចទាំងនោះ បានធ្វើអោយមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគាត់មានដីស្រែ ចំការ ដែលពួកគាត់មាននៅក្នុងតំបន់ស្នើសុំដោយក្រុមហ៊ុនមួយចំនួនផងដែរ ។

៤-អំពីបញ្ហាសេដ្ឋកិច្ចៈ ថាបើយើងទុកដីនេះទៅមានចំណេញអ្វីខ្លះ? អាចទទួលបាននូវចំណូលថវិកាជាតិប៉ុន្មាន? ហើយប្រជាជនអាចទទួលចំណូលបានប៉ុន្មានក្នុងមួយឆ្នាំៗអំពីការប្រមូលផល-អនុផលព្រៃឈើទាំងនោះ ឧទាហរណ៍ ការប្រមូលជ័រឈើជាដើមនោះ ហើយបើយើងយកដីនោះ វិនិយោគឱ្យក្រុមហ៊ុនធ្វើការអភិវឌ្ឍន៍ តើអាចនឹងទទួលបានអ្វីខ្លះ? តើទុកដីទាំងនោះឱ្យនៅដដែលទទួលបានផលប្រយោជន៍ច្រើន ឬក៏យកដីទៅធ្វើការអភិវឌ្ឍន៍បានចំណេញច្រើនជាង? សរុបទៅ បើពិនិត្យនៅលើទីតាំងដីស្នើសុំក្រុមហ៊ុននេះនៅលើផែនទី ឃើញថា មានប្រមាណជាមួយម៉ឺនហិកតា ដែលដីនេះអាចនឹងមានពាក់ព័ន្ធដីស្រែ ចំការ របស់ប្រជាពលរដ្ឋក៏តិចតួចដែរ តែជាក់ស្តែងបច្ចុប្បន្ន មិនដឹងថាមានប៉ុន្មានច្បាស់លាស់នៅឡើយទេ ទាល់តែមានការចុះទៅស្រង់ចំនួនដីពាក់ព័ន្ធ និងធ្វើអត្តសញ្ញាណកម្ម ទាំងអស់គ្នាទើបច្បាស់លាស់ អំពីបញ្ហាពាក់ព័ន្ធទាំងអស់នោះ។ ដូចនេះដើម្បីឱ្យបានច្បាស់ សុំមន្ទីរជំនាញដែលពាក់ព័ន្ធមួយៗ ធ្វើការមានយោបល់អំពីគំរោងស្នើសុំដីសម្បទានរបស់ក្រុមហ៊ុនទាំងពីនេះ តែមុននឹងមន្ទីរជំនាញមានយោបល់ សុំឱ្យខាងក្រុមការងារធ្វើបទបង្ហាញអំពីរបាយការណ៍ចុះសិក្សាជំហានដំបូងជាមុនសិន ដើម្បីឱ្យដឹងអំពីចំណុចវិជ្ជមាន និងអំពីចំណុចអវិជ្ជាមាន ទើបមន្ទីរជំនាញពាក់ព័ន្ធ មានមតិបន្ថែមលើបញ្ហាទាំងនោះ ។

**លោក ចាន់ វណ្ណា** : ចំពោះការធ្វើបទបង្ហាញនៅក្នុងកិច្ចប្រជុំនាពេលនេះ គឺក្រុមហ៊ុន អេចអិលអេច អេហ្គ្រីខលឈ័រ (ខេមបូឌា) ខូអិលធីឌី ដែលបានស្នើសុំដីសម្បទានសេដ្ឋកិច្ចពាក់ព័ន្ធនឹងឃុំពីរគឺ ឃុំ សង្កែសាទប និង ឃុំ ត្រពាំងជោ ខេត្តកំពង់ស្ពឺ។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត ដែលបាន ចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ ២០០៨ ។ ក្រុមហ៊ុនបានស្នើសុំដីសម្បទាន សេដ្ឋកិច្ចចំនួន ៩៩៨៥ ហិកតា ដើម្បីវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម ស្ថិតនៅក្នុង ឃុំ សង្កែសាទប និង ឃុំ ត្រពាំងជោ ខេត្តកំពង់ស្ពឺ។ ក្រុមហ៊ុនមានគោលបំណងធ្វើការអភិវឌ្ឍន៍ប្រែក្លាយដីព្រៃរល្បោះរិចរិលអោយទៅជាតំបន់កសិ-ឧស្សាហកម្ម (ដំណាំពោត) និងចូលរួមធ្វើជាដៃគូអភិវឌ្ឍន៍ក្នុងស្រុកដ៏ល្អមួយ ជាមួយរាជរដ្ឋាភិបាល ដើម្បី

Draft

ជួយបង្កើន ផលិតភាព ការងារដល់ប្រជាពលរដ្ឋនៅតាមតំបន់ដាច់ស្រយាល ព្រមទាំងជួយលើកស្ទួយជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ឱ្យកាន់តែប្រសើរឡើង។

ដីសម្បទានដែលក្រុមហ៊ុន **HLH AGRICULTURE (CAMBODIA) Co., Ltd**។ ស្នើសុំមាន ទំហំ ៩៩៨៥ហិកតា ដែលមាន ភូមិសាស្ត្រឃុំត្រពាំងជោ និងឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ដីនេះមាន ព្រំប្រទល់ខាង កើតស្របតាមផ្លូវលេខ៥២ ជាប់ព្រំប្រទល់ភូមិដំបងវិញ ច្រកទៀក និងអូរតោង និងព្រំប្រទល់ក្រុមហ៊ុនកំពង់ស្ពឺ ស៊ូហ្គ៊ីរ **(14)**៤០៤០១៤ -១២៩៤២៤៤ **(7)**៤០៤០២៨ -១៣០០១៣៨ **(6)**៤០៣២០០ -១៣០០៧៤១ **(5)**៤០៣២៣៧ -១៣០១២៧៩ **(4)**៤០៤០១០ -១៣០១៣០៥ **(3)**៤០៤០២៦ -១៣០៦០៩៤ **(2)**៤០២២២១ -១៣០៧៦២៣ និង **(1)**៤០២២៤២ -១៣១១៦៣៤ ខាងលិចស្ថិតត្រង់ចន្លោះចំណុចនិយាមកា១៩៥ឬ៣៩៣១៧៣-១៣១៥៤០៩ **(79)** ៣៩២៩០២ -១៣០៥៩៩៣ **(72)**៣៩៥១៦១-១៣០៤៩៥៩ **(47)**៤០០០៤១-១៣០៤២៨៤ **(46)**៤០០២៨៤-១៣០៤២៣៧ **(37)**៤០១០៨៧-១២៩៩៨៤៥ **(34)**៣៩៩០១៤-១២៩០០១៤ **(26)**៤០០១១១-១២៩៧៤៦០ និង **(22)**៣៩៩០០៩-១២៩៥៧៣៣ ជាប់អូរសំរោង និងភ្នំរាំងកាល រីឯខាងជើងស្ថិតនៅចន្លោះចំណុចនិយាមកា **(95)**៣៩៣១៧៣-១៣១៥៤០៩ **(96)** ៣៩៤០៨៨-១៣១៥៩៩៦ **(97)**៣៩៥២៤៩-១៣១៥៩៩៦ **(100)**៣៩៦៥៧៧-១៣១២៤៥០ **(101)** ៣៩៦៦០៣-១៣០៩២៩៧**(103)**៣៩៨៩៣១-១៣០៩១៣៥ **(104)**៣៩៩៤៤៧-១៣១០១៧៤ **(106)** ៤០១០០០-១៣១០៥០៩ **(107)** ៤០១៤១៣-១៣១១៦៥០ និង **(1)** ៤០២២៤២-១៣១១៦៣៤ ជាប់ព្រំប្រទល់ឃុំសង្រែ និងឃុំព្រងិល ស្រុកភ្នំក្រវ៉ាញ ចំណែក ខាងត្បូងស្ថិតនៅចន្លោះចំណុចនិយាមកា **(14)**៤០៤០១៤ -១២៩៤២៤៤ **(15)**៤០៣៦៥៤-១២៩៤០៩១ **(20)**៤០២០០៩-១២៩៤៥៤៨ និង **(22)**៣៩៩០០៩ -១២៩៥៧៣៣ ស្របតាមបណ្តោយស្ទឹងត្រាងក្រាង និងក្បែរភ្នំតេ។

វិធីសាស្ត្រស្រាវជ្រាវ-ភាពជឿជាក់ និងទំហំនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមបឋមទៅលើការអង្កេតអេកូឡូស៊ីៈ ក្រុមការងារបានសិក្សាផ្អែកលើផែនទី០២ប្រភេទគឺ (១)ផែនទីប្រើប្រាស់ដី និងគំរបព្រៃ និង (២)ផែនទីភូមិសាស្ត្ររដ្ឋបាលដោយជ្រើសរើសយកចំណុចនិយាមកា តាមលក្ខណៈចៃដន្យទៅតាមប្រភេទនៃសារព័ន្ធរុក្ខជាតិនិមួយៗក្នុងតំបន់ដីសម្បទានស្នើសុំ។ ចំណែកឯការសិក្សាវាយតំលៃស្ថានភាពគំរបព្រៃ និងការប្រើប្រាស់ដីតាមរយៈរូបភាពថតពីអាកាសដោយប្រើប្រាស់ ឧបករណ៍ Paramotor ហើយការសិក្សាអំពីស្ថានភាពសង្គមសេដ្ឋកិច្ចក្រុមការងារបានធ្វើការពិគ្រោះយោបល់ជាមួយនិងអាជ្ញាធរមូលដ្ឋាន (ខេត្ត ស្រុក ឃុំ និងភូមិ) មន្ទីរអង្គភាព និងប្រជាជនក្នុងសហគមន៍មូលដ្ឋានដែលមានការពាក់ព័ន្ធ និងកន្លែងផ្ទាល់។ ហើយលទ្ធផលនៃការស្រាវជ្រាវដែលផ្អែកទៅលើធនធានរូបវន្ត នៃដំណើរប្រព្រឹត្តទៅនៃបាតុភូតភូគព្ភសាស្ត្រនេះបានទទួលរង នូវឥទ្ធិពលអាកាសធាតុ ពេលវេលា ឋានលេខា និងដំណើរប្រព្រឹត្តទៅតាមលក្ខណៈជីវសាស្ត្រ

ធម្មជាតិ លក្ខណៈជីវសាស្ត្រដែលបង្កឡើងដោយមនុស្ស សត្វ និងបាក់តេរី។ កត្តាទាំងអស់នេះអាចបញ្ជាក់ដោយផ្ទាល់ និងដោយប្រយោលអំពីដីដែលមានលក្ខណៈ ជាអាស៊ីត ពណ៌ វចនាសម្ព័ន្ធ ជីជាតិ លទ្ធភាពផលិតកម្ម និងភាពជ្រាបទឹក។ យោងតាមផែនទីភូតគព្ភសាស្ត្រ របស់ក្រុមហ៊ុន **HLH AGRICULTURE (CAMBODIA) Co., Ltd** បង្ហាញថាដីសម្បទាននេះមានសិលាមេមួយ៤ប្រភេទគឺ (១) Flood Rian (៧២៦,៥ហិកតា) ស្មើនឹង ៧,២៧ ភាគរយ នៃផ្ទៃដីសរុប ។ (២) Granite or g3-4coase grianed granite (៣១៧,៨ ហិកតា) ស្មើនឹង ៣,១៨ ភាគរយ នៃផ្ទៃដីសរុប។ (៣) Pediments (៨៩១៩,២ ហិកតា) ស្មើនឹង ៨៩,៣៣ ភាគរយ នៃផ្ទៃដីសរុបនិង(៤) Rydite (២១,៥ហិកតា) ស្មើនឹង 0,២២ ភាគរយ នៃផ្ទៃដីសរុប។ ចំណែកឯចំនាត់ថ្នាក់ប្រភេទដីមានចំនួន៣ប្រភេទគឺៈ (១) Acid Lithosols (៥៦0 ហិកតា) ស្មើនឹង ៥,៦0 ភាគរយ(២) Grey hydromorphics (១៦៣0,៨ ហិកតា) ស្មើនឹង១៦,៣៣ ភាគរយ (៣) Planpodzols (៧៧៩៤ហិកតា) ស្មើនឹង ៧៨,0៥ ភាគរយ ហើយបើយោងតាមលក្ខណៈដី និងឋានលេខា ដីសម្បទាននេះបានគ្របដណ្តប់ទៅដោយដីជាច្រើនប្រភេទ ដែលជាដីមានជីជាតិ សមស្រប សំរាប់ដំណាំកសិ-ឧស្សាហកម្ម និងដំណាំផ្សេងៗ។ យោងតាម **ឋានលេខា** ដីនៅក្នុងតំបន់ដែលក្រុមហ៊ុនបានស្នើសុំភាគច្រើនដីមានស្ថានភាពស្ទើររាបស្មើ តែមានតំបន់មួយចំនួនជាខ្ពង់រាបមានជំរាលពី៥-២0និងអាចលើសពី២0ដឺក្រេ សរុបប្រមាណជា១១៤.៧ហិកតាប៉ុណ្ណោះ។ ប្រភេទដីភាគច្រើនជាដីល្បាយខ្សាច់ក្រម៉ៅ និងដីក្រហមដោយកន្លែង។ តាមការសង្កេត និងការប្រមូលទិន្នន័យពីខាង ធនធានអេកូឡូស៊ី បានបង្ហាញថា សារព័ន្ធរុក្ខជាតិព្រៃ ឈើក្នុងតំបន់គំរោងស្នើសុំទាំងពី២មានប្រភេទគំរូព្រៃចំនួន៣គឺ ព្រៃស្រោង ពាក់កណ្តាលស្រោង និងព្រៃល្បោះ។ ហើយរចនាសម្ព័នថ្នាក់ក្រោមជាប្រភេទកូនឈើតូចៗដែល ទើបលាស់ថ្មី និងស្មៅ ព្រិច។ តាមរយៈការចុះអង្កេតដោយផ្ទាល់ និងការសិក្សាផ្ទៀងផ្ទាត់ ដោយផ្អែកលើផែន ទីគំរបព្រៃឈើឆ្នាំ២00២ ឃើញថាស្ថានភាពព្រៃទាំងនេះធ្លាប់ទទួលរងការធ្វើអាជីវកម្ម គួបផ្សំនឹងមានភ្លើងឆេះព្រៃ ដោយសារសកម្មភាពប្រជាជន ដែលរស់នៅក្បែរៗនោះ ទើបធ្វើអោយចំនួនព្រៃទាំង នោះមានការថយចុះ យ៉ាងខ្លាំងហើយសារពន្ធ័រុក្ខជាតិ ជំនាន់ក្រោយពិបាកក្នុងការលូតលាស់ និងដោយសារគំរបព្រៃស្ទើរបាត់បង់មួយភាគធំ ។ ក្នុងដំណើរអង្កេត និងសំភាសន៏ជាមួយប្រជាជនដែលរស់នៅក្បែរទីនោះ និងប្រជាជន ដែលធ្លាប់ ឆ្មុះសត្វនៅតំបន់នេះបានអោយដឹងថា នៅក្នុងដីព្រៃសម្បទាននេះ បច្ចុប្បន្នពុំសូវមានវត្តមាន សត្វព្រៃគួរអោយ កត់សំគាល់ក្រៅពីជ្រូកព្រៃ និងឈ្លូស និងមិនឃើញមានវត្តមានសត្វព្រៃធំៗទេ។ ក្រៅពីការធ្វើអង្កេតដើរចូលទៅក្នុងព្រៃ ក៏មានក្រុមការងារធ្វើការហោះហើរថតពីលើអាកាសដោយប្រើឧបករណ៍ Paramotor ដើម្បីថត យករូបពិតពីអាកាស ហើយធ្វើការប្រៀបធៀប ជាមួយនឹងរូបភាពប្រើប្រាស់ដីធ្លី និងគំរបព្រៃឆ្នាំ២00២ និងការធ្វើអង្កេតអេកូឡូស៊ីជាក់ស្តែងនៅលើទីវាល (ផែនទីគន្លងវិស្សុតកម្មកំពស់ ៧0៣ម)។ តាមរយៈរូប ភាព Photo Index Maps បង្ហាញអោយឃើញថាគំរបព្រៃ និងធនធានព្រៃឈើមានលក្ខណៈវិចិរិលនៅទូទាំងដីសម្បទាន ទាំងមូលស្ថានភាពគំរបព្រៃត្រូវបានបើកចំហមួយផ្នែកធំ ហើយព្រៃទាំងនេះមិនមានឈើដែលមានតំលៃពាណិជ្ជកម្ម នៅសេសសល់

Draft

ច្រើនទេ។ ដោយសារនៅរដូវវស្សា ដូច្នេះហើយបានជាយើង សង្កេតឃើញស្ថានភាពព្រៃមានលក្ខណៈបៃតងស្រស់ទាំងស្លឹកឈើ ទាំងរចនាសម្ព័ន្ធថ្នាក់ក្រោមដែលជាប្រភេទកូនឈើតូចៗ ទើបលាស់ថ្មី និងស្មៅព្រិច។ អំពីធនធានសង្គម សេដ្ឋកិច្ច និងការអភិវឌ្ឍន៍ផ្នែក សេដ្ឋកិច្ចក្នុង តំបន់នេះមានលក្ខណៈខុសៗគ្នា ទៅតាមទីប្រជុំជន ខេត្ត ស្រុក និងជនបទ។ ចំណែកឯប្រជាជន ភូមិចំបក់ ត្រាង កោះដូង្គី ពុទ្រា សំរោង លាក់តាន ក្រវៀក ក្បាលដំរី ច្រកទៀក តាដិល ឃុំត្រពាំងជោ និងឃុំសង្កែ សាទប ដំបងវេញ កន្ទូត ជំនាប់ តាដែស ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។ ក្រៅពីការប្រកបរបរស្រែចំការ ពួកគាត់បានចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និងការចូលទៅក្នុងព្រៃដើម្បីកាប់ឈើ រកផល-អនុផលព្រៃឈើដូចជា ចាក់ជ័រ កាប់អុស បេះផ្សិត និងបន្លែបង្កាផ្សេងៗសំរាប់តម្រូវការក្នុងគ្រួសារ ឬលក់ដូរផងដែរ។ ហើយ ចំណូល ប្រចាំឆ្នាំរបស់គ្រួសារ ក្នុងសហគមន៍មានលក្ខណៈផ្សេងៗគ្នា អាស្រ័យទៅនឹងការប្រកបមុខរបររបស់គ្រួសារនីមួយៗ ។ ការប្រកបរបរស្រែចំការរបស់ពួកគាត់ហាក់ដូចជាមិនទាន់អាចអោយពួកគាត់ មានភាពល្អប្រសើរ សំរាប់តំរូវការគ្រួសារនៅឡើយទេ ក៏យើងសង្កេតឃើញមានគ្រួសារភាគច្រើនប្រើប្រាស់រទេះ គោជាមធ្យោបាយដឹកជញ្ជូន និងធ្វើដំណើរក្នុងតំបន់នៅឡើយ ។ យោងទៅលើលទ្ធផលនៃការពិគ្រោះយោបល់ ជាមួយអាជ្ញាធរឃុំ ភូមិ និងប្រជាជនសហគមន៍ដែលពាក់ព័ន្ធ និងការធ្វើអង្កេតអេកូឡូស៊ីជាក់ស្តែងលើទីវាល ក្រុមការងារយល់ឃើញថា គំរោងអភិវឌ្ឍន៍ដាំដំណាំកសិ-ឧស្សាហកម្មលើទីតាំងដីសម្បទាន សេដ្ឋកិច្ចដែលក្រុមហ៊ុនបានស្នើសុំ អាចនឹងនាំមកនូវហេតុប៉ះពាល់បរិស្ថាន និងសង្គមមួយចំនួនដូចជាការផ្លាស់ប្តូរនូវលំនាំ នៃការប្រើប្រាស់ដីទ្រង់ទ្រាយធំ ដោយការប្រែក្លាយដីព្រៃធម្មជាតិទៅជាចំការដំណាំកសិ-ឧស្សាហកម្ម នឹងបណ្តាលអោយកខ្វក់ដល់ ប្រភពទឹកក្នុងរយៈពេលខ្លីនិងមធ្យម។ ជ័រដែលហូរចេញពីគំនរឈើដែលឈូសគរទុកនឹងបង្ក អោយកខ្វក់ដល់ ផ្លូវទឹក ជាពិសេស នៅពេលមានភ្លៀងធ្លាក់ខ្លាំង។ កាកសំណល់ ឬគំនរសំរាម(ឈើ) នឹងធ្វើអោយមានការ កកស្ទះដល់ការហូររំដោះទឹកនៅ ពេលមានភ្លៀងធ្លាក់ខ្លាំង ឬក៏ធ្វើឱ្យស្អិតក្តាំងដី និងមានការហូរច្រោះដី បណ្តាលពីការឈូសឆាយដីព្រៃ អាចបង្កអោយប្រព័ន្ធ ផ្លូវទឹក (អូរ និងព្រែក) នៅក្នុងតំបន់នោះរាក់ដោយកំណល្បាប់និងខ្សាច់។ ការបំភាយឧស្ម័នកាបូនិក និងសារធាតុពុលបរិយាកាសផ្សេងៗទៀតទៅក្នុងបរិយាកាស បង្កដោយការដុតចោលនូវសំណល់ឈើដែលមិនប្រើប្រាស់ ការធ្លាក់ចុះជាទូទៅនូវលទ្ធភាព និងដំណើរការសំយោគ ឧស្ម័នកាបូនិក និងឥទ្ធិពលទៅលើស្រទាប់អូសូន។ ការកំណើនយ៉ាងគំហុកនូវចំនួនកម្មករនៅ ក្នុងតំបន់និងការ បង្កភាពកខ្វក់ទៅលើដី ដោយកាកសំណល់របស់គ្រឿងចក្រសកម្មភាពពាក់ព័ន្ធជាមួយនឹងការឈូសឆាយដាំដុះ ប្រមូលផល និងកែច្នៃ ដោយសាការចោលកាកសំណល់រឹង និងរាវទៅក្នុងធម្មជាតិ។ ហេតុប៉ះពាល់វិជ្ជមានទៅលើបរិស្ថាន នឹងធ្វើអោយស្ថានភាពគំរបព្រៃ និងធនធានព្រៃឈើនៅតំបន់ជុំវិញនោះដុះល្អប្រសើរឡើង វិញដោយសារមានការផ្លាស់ប្តូរ នូវលំនាំនៃការប្រើប្រាស់ធនធានធម្មជាតិទាំងនោះ (ពីការប្រើប្រាស់ ផល-អនុផលព្រៃឈើ មកជាឥដ្ឋនិងស៊ីម៉ង់ត៍ ពីការប្រើជីវៈម៉ាស់និងឧស មកជាប្រេងឥន្ទនៈ ឬ ឧស្ម័ននិង ហ្គាស) ពីសំណាក់សហគមន៍មូលដ្ឋាន ពីព្រោះពួកគាត់នឹងមានជំរើស ជាច្រើនក្នុងការផ្គត់ផ្គង់ ជីវភាពរបស់ពួកគាត់។ បង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់ដី តាមរយៈការប្រែក្លាយតំបន់ព្រៃ

Draft

ទៅជាតំបន់ទេសចរណ៍ធម្មជាតិ ឬព្រៃដែលមានតំលៃពាណិជ្ជកម្មទាបទៅជាតំបន់អភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម។ ហេតុប៉ះពាល់សង្គមនៅក្នុងទីតាំងដីសម្បទានដែលក្រុមហ៊ុនបានស្នើសុំមានការពាក់ព័ន្ធ និងដីស្រែចំការរបស់ប្រជាជនមួយចំនួនផងដែរ ដែលអាចនឹងប៉ះពាល់ដល់អារម្មណ៍ និងផលប្រយោជន៍របស់ពួកគាត់ ធ្លាប់ទទួលបានផល-អនុផល ព្រៃឈើពីក្នុងតំបន់ក្រុមហ៊ុនស្នើសុំ។ ប្រជាជនមានការព្រួយបារម្ភចំពោះការអនុវត្តន៍របស់ក្រុមហ៊ុនធ្វើមិនត្រឹមត្រូវតាមកិច្ចសន្យានៅពេលដែលទទួលបានសិទ្ធិប្រទានពីរដ្ឋាភិបាល។ លើការប៉ះពាល់ដល់ដីស្រែចំការរបស់ពួក គាត់ធ្លាប់ធ្វើរាល់ឆ្នាំនៅទីនោះ នឹងអាចមានការជាន់គ្នាមួយផ្នែកជាមួយអាជ្ញាប័ណរុករករ៉ែរបស់ក្រុមហ៊ុនផ្សេងផងដែរ។ ដែលតាមការសិក្សាបានបានអោយដឹងថា ដីស្នើសុំវិនិយោគរបស់ក្រុមហ៊ុន **HLH AGRICULTURE (CAMBODIA) Co., Ltd** តាមការសិក្សាបានបានអោយដឹងថា ដីនេះមានប៉ះពាល់លើព្រៃសហគមន៍ជនជាតិដើមស្អួយកោដ្ឋវ្តី និងដីស្រែចំការពួកគាត់សរុបប្រមាណជា២១៦៤,២៣ហិកតា។ ប៉ះពាល់លើដីលំនៅដ្ឋាន ស្រែ ចំការ ប្រជាពលរដ្ឋភូមិ ក្បាលដំរីនឹងភូមិលាក់តាន សរុបប្រមាណជា ៩២៧,៣៣ ហិកតា។ មានប៉ះពាល់លើព្រៃសហគមន៍ជនជាតិក្រាំងចំបក់ដែលមានដីស្រែ ចំការ និងទីសក្ការៈ របស់ជនជាតិដើមភាគតិចស្អួយ ពួកគាត់សរុបប្រមាណជា១៦៩៥,៤៥ហិកតា។ មានប៉ះពាល់លើដីស្រែ ចំការ ប្រជាពលរដ្ឋភូមិពោធិ៍មាស និងភូមិច្រកទ្បេកសរុបប្រមាណជា១១៥,២៩ហិកតា។ មានប៉ះពាល់លើដីស្រែចំការ ប្រជាពលរដ្ឋភូមិដំបងវេញ ភូមិជន្ទាប់ កន្ទួត ក្រាំងពង្រនិងភូមិតាដែស សរុបប្រមាណជា ២៣៩,៦០ ហិកតា។ ដូចនេះផ្ទៃដីប៉ះពាល់សរុបទាំងអស់សរុបចំនួន ៥១១៤,៩៣ហិកតា ដែលផ្ទៃដីទាំងនេះ សរុបទាំង ផ្ទៃដីដែលប្រជាពលរដ្ឋកាប់ទន្រ្ទានដោយអនធិបតេយ្យប្រមាណជា២៨,២៦ ហិកតាផងដែរ។

ចំពោះសារៈប្រយោជន៍ដែលនឹងទទួលបានពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចគឺៈ(១) ការផ្តល់នូវកាលានុវត្តភាពការងារថ្មីៗ ដល់ប្រជាពលរដ្ឋរស់នៅតំបន់ក្បែរៗនោះ និងប្រជាជន ពីតំបន់ដទៃទៀត។ ដែលនឹងធ្វើអោយជីវភាពរស់នៅរបស់ពួកគាត់មាន លក្ខណៈល្អប្រសើរជាងមុន ហើយការកើនឡើងនូវកំរិតជីវភាពរស់នៅនេះនឹងផ្តល់អោយពួកគាត់នូវជំរើសផ្សេងៗទៀតក្នុង ការប្រកបរបរចិញ្ចឹមជីវិត។ ឧទាហរណ៍ពួកគាត់ អាចផ្លាស់ប្តូរការរស់នៅរបស់គាត់ពីការប្រាស្រ័យ លើធនធានធម្មជាតិ ទៅជាមុខរបរផ្សេងៗទៀតមានដូចជាៈ ការបំរើការងារជាបុគ្គលិក-កម្មករនៅ ក្នុងគំរោងរបស់ក្រុមហ៊ុន ឬតាមកសិដ្ឋាន និងឧស្សាហកម្មកែច្នៃជាដើម។ (២)ការអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មនៅក្នុងតំបន់នោះនឹងនាំអោយ មានការជំរុញសកម្មនូវចរន្ត សេដ្ឋកិច្ចនៅក្នុងភូមិ ឃុំ ស្រុក និង ខេត្ត តាមរយៈការបង្កើត អោយនូវសេចក្តីត្រូវការស្បៀង (ស្រូវអង្ករ បន្លែបង្ការ និងត្រីសាច់ផ្សេងៗ) និងការផលិតស្បៀងដើម្បីផ្គត់ផ្គង់។ (៣)ធ្វើអោយប្រជាជនក្នុងតំបន់មានការអភិវឌ្ឍន៍ផ្នែកផ្នត់គំនិត តាមរយៈការផ្លាស់ប្តូរបទពិសោធន៍ ការងារពីសំណាក់មនុស្សចំណូលថ្មី ឬក៏ការទទួលបានការបណ្តុះបណ្តាលផ្នែកជំនាញបច្ចេកទេសកសិកម្មផ្សេងៗពីសំណាក់ក្រុមហ៊ុន។ (៤) ផ្តល់ឱកាសអោយប្រជាពលរដ្ឋ

Draft

ក្នុងសហគមន៍ទទួលបាន នូវសេវាសាធារណៈពេញលេញដូចជា សេវាអប់រំ (ក្មេងៗមានឱកាសទៅសាលារៀនគ្រប់ៗគ្នា) សេវាសុខភាព សេវាគមនាគមន៍ ថាមពល អគ្គិសនី និងទឹកស្អាតជាដើម។

ជាលទ្ធផលហេតុប៉ះពាល់ពហុវិជ្ជមាននេះ អាចនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកំពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្រនៅក្នុងគ្រួសាររបស់ពួកគាត់។

កាលពីថ្ងៃទី ២៤-៣១ ខែ តុលា ឆ្នាំ ២០០៩ ក្រុមការងាររបស់ **ហ្គ្រីន ខនសាល់ធិនស៊ី ហ្វឹម** បានចុះធ្វើការពិគ្រោះយោបល់ ជាមួយអាជ្ញាធរ ឃុំ ភូមិ និងប្រជាជន សហគមន៍មូលដ្ឋាន (មានទីតាំងស្ថិតនៅភូមិ ចំបក់ ត្រាង កោះដូនី ពុទ្រា សំរោង លាក់តាន ក្រវៀក ក្បាលដំរី ច្រកទៀក តាដិល ឃុំត្រពាំងជោ និងភូមិ ដំបងវេញ កន្ទួត ជំនាប់ តាដែស ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ) សរុបចំនួន ៣១៣ នាក់ កាល ពីថ្ងៃទី ២៤-៣១ ខែ តុលា ឆ្នាំ ២០០៩ ពួកគាត់បានមានយោបល់ និងសំណូមពរដូចខាងក្រោមៈ

Draft

បើសិនមានការប៉ះពាល់ដល់ដីរបស់ប្រជាជនសុំធ្វើការដោះស្រាយឱ្យ ប្រជាជនអោយ បានសមស្រប ព្រោះជាដីស្រែចាស់ដែលប្រជាជនបានបោះបង់ចោលដោយសារតែសង្គ្រាម ក្រោយមកប្រជាជនបានត្រឡប់មកកាន់កាប់ និងធ្វើស្រែឡើងវិញតាំងពីឆ្នាំ ១៩៩៦-៩៧ មកម្លេះ។ និងសូមកាត់ដីព្រៃសហគមន៍ចំនួន ២៤៥១ ហិកតា ដែលបង្កើតឡើង នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៥ ដោយក្រសួងបរិស្ថានចេញពីតំបន់វិនិយោគ។ លើសពីនេះទៅទៀត សុំឱ្យក្រុមហ៊ុន ចូលរួមអភិវឌ្ឍន៍សហគមន៍ នូវហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដែលរួមមាន ជួយធ្វើផ្លូវ សាលារៀន អន្លង់ទឹក ប្រឡាយទឹក សំរាប់បង្កបង្កើនផល ស្រែចំការជាដើម។

សុំឱ្យមានការរក្សាទុកព្រៃឈើមួយចំនួនប្រយោជន៍ ដើម្បីបានប្រើប្រាស់នៅក្នុងសហគមន៍របស់ពួកគាត់ និងសុំរក្សាទុកដើមជ័រច្បោះរបស់ពួកគាត់ផងដែរ។ ធ្វើដូច្នេះប្រជាជនមានរំពឹងនឹងថាទទួលបានផលប្រយោជន៍ដល់ពួកគាត់មិនខាន តាមរយៈការផ្តល់នូវការងារសមស្រប និងកំរៃសមរម្យ មិនចាំបាច់ធ្វើចំណាកស្រុកទៅឆ្ងាយទេ មិនតែប៉ុណ្ណោះក្រុមហ៊ុននឹងជួយអភិវឌ្ឍន៍ដល់សហគមន៍ទៀតផង។ នៅពេលក្រុមហ៊ុនមកនឹងត្រូវធ្វើផ្លូវដើម្បីនាំផលចេញមិនខាន ដូចនេះ ប្រជាជនក៏នឹងអាចប្រើប្រាស់ផ្លូវទាំងនោះផងដែរ ម្យ៉ាងវិញទៀតពួកគាត់ បានធ្វើការស្នើសុំយ៉ាងទទូចថា នៅពេលដែលក្រុមហ៊ុនបញ្ជាឱ្យខាងក្រុមការងារចុះទៅធ្វើការឈូសឆាយសុំធ្វើ យ៉ាងណាកុំមានការឈូសច្រឡំព្រំច្រើនលើកច្រើនសារពេក នឹងសុំចាត់អ្នកដែលឈូសឆាយ និងអ្នកកំណត់ព្រំប្រើប្រាស់ឧបករណ៍ **ជីភីអេស** ឱ្យត្រូវតាមចំណុចនិយាមកាដែលបានព្រមព្រៀងគ្នាដែលក្រុមការងារបានចុះកំណត់រួចកន្លងមក។ គំរោងស្នើសុំដីសម្បទានសេដ្ឋកិច្ចនេះមានប៉ះពាល់នឹង ភូមិចំបក់ ត្រាង កោះដូនី ពុទ្រា សំរោង លាក់តាន ក្រវៀក ក្បាលដំរី ច្រកទៀក តាដិល ឃុំត្រពាំងជោ និងភូមិ ដំបងវេញ កន្ទួត ជំនាប់ តាដែស ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ) ប្រាកដមែន។ ដូចនេះក្រុមហ៊ុនត្រូវមាន កិច្ចសហការល្អជាមុនជាមួយអាជ្ញាធរ និងនាយកដែនជំរកសត្វព្រៃ ដើម្បីធ្វើការដោះស្រាយដោយផ្អែកទៅលើកិច្ចសន្យារ

រវាងក្រុមហ៊ុន និងក្រសួងបរិស្ថាន។ បើធ្វើដូចនេះប្រជាពលរដ្ឋនៅក្នុងសហគមន៍មូលដ្ឋាន នឹងចូលរួមគាំទ្រចំពោះការធ្វើវិនិយោគរបស់ក្រុមហ៊ុនក្នុងការអភិវឌ្ឍន៍ដាំដំណាំកសិ-ឧស្សហកម្ម ដោយសារតែប្រជាពលរដ្ឋមិនមានការបាត់បង់ដីរបស់ពួកគាត់ ។

ដូច្នេះជាអនុសាសន៍ ក្រុមហ៊ុនត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ចុះទៅពិនិត្យនឹងធ្វើការកំណត់ព្រំប្រទល់ អោយបានច្បាស់លាស់រវាងព្រំប្រទល់ព្រៃសហគមន៍ និងព្រំប្រទល់ដីសម្បទានស្នើសុំ ដើម្បីជៀសវាងនូវបញ្ហារវាងក្រុមហ៊ុនវិនិយោគនិងសហគមន៍។ ហើយនៅក្នុងដំណើរប្រតិបត្តិការគំរោង សាមីវិនិយោគិន ត្រូវអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថានទៅតាម វិធានការណ៍នានាដូចមានកំណត់នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម និងផែនការគ្រប់គ្រងបរិស្ថាន ដែលមានស្ថាប័នជំនាញ និងអាជ្ញាធរពាក់ព័ន្ធតាមដានពិនិត្យនឹងវាយតំលៃ ទៅលើសកម្មភាពនៃការអភិវឌ្ឍន៍របស់វិនិយោគិន ជាប្រចាំទៅតាមកម្ម វិធីដូចមានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។

Draft

**ឯកឧត្តម កង ហ៊ាង** អភិបាលខេត្តកំពង់ស្ពឺ: តាមការធ្វើបទបង្ហាញរបស់ក្រុមការងារ ផ្នែកបរិស្ថានជំហានដំបូងឃើញថា មានការចុះសិក្សា ទៅតាមបច្ចេកទេស ដោយមានការដើរចូលក្នុងព្រៃ ក៏ដូចជាការហោះហើរថតគំរបព្រៃពីលើអាកាស ទន្ទឹមនឹងនោះក៏មានការជួបសំភាសផ្ទាល់ជា មួយប្រជាជនរស់ នៅជុំវិញតំបន់ដីដែលក្រុមហ៊ុនបានស្នើសុំ រួមទាំងអាជ្ញធរភូមិឃុំផងដែរ ដូចនេះដើម្បីឱ្យកាន់តែច្បាស់ អំពីទីតាំងរបស់ដីនោះមានពាក់ព័ន្ធកិតណាសុំឱ្យខាងអភិបាលស្រុកធ្វើការបំភ្លឺជាមុនសិន ហើយបន្ទាប់មកសុំ តំណាងមន្ទីរពាក់ព័ន្ធចូលរួមមាន យោបល់ទាំងអស់គ្នា ព្រោះនេះជារឿងដែលត្រូវមានការទទួលខុសត្រូវទាំងអស់គ្នា ជៀសវាងទៅថ្ងៃក្រោយឆ្លើយដាក់គ្នាមិនដឹងមិនឮសូមអញ្ជើញ។

លោក **ចែម សារីម** អភិបាលស្រុកឱរ៉ាល់ : ខ្ញុំសូមញ្ជាក់ថាចំពោះដីសម្បទានរបស់ក្រុមហ៊ុនដែលបានស្នើសុំ កាលពីថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៩ គឺមានក្រុមការងារចុះទៅធ្វើការសិក្សាផ្ទាល់ នៅលើទីតាំងនោះមែនហើយបន្ទាប់មកក៏ឃើញមានការហោះហើរ នៅលើទីតាំងដីនោះដែរ តែចំពោះទីតាំងដែលក្រុមហ៊ុនស្នើសុំនេះ ខាងអាជ្ញាធរស្រុកមិនបានចុះសិក្សាដឹងច្បាស់នោះទេ ព្រោះក្រុមហ៊ុនកន្លងមកមិនដែលបានជូនដំណឹង ឬមកសហការជាមួយថ្នាក់ស្រុកដែរ នៅពេលដែលទទួលបាន ច្បាប់ពីលើហើយចូលទៅធ្វើការបោះបង្គោលកំណត់ព្រំ តែនៅពេលនោះមិនមានការរសើបពីសំណាក់ប្រជាជនប៉ុន្មាននោះទេ ពេលមានការតវ៉ាខ្លាំងគឺនៅពេលមានការឈូសឆាយជីកក្រវ៉ាត់ព្រំដីរបស់ក្រុមហ៊ុននោះតែម្តង ។ នៅពេលដែលមានការតវ៉ាពីសំណាក់ប្រជាពលរដ្ឋ ខាងស្រុកក៏ចុះទៅធ្វើការសម្របសម្រួល និងដោះស្រាយ ហើយជាលទ្ធផលនៃការចុះសិក្សានោះឃើញថា មានដីពាក់ព័ន្ធនោះប្រហាក់លបហែល និងរបាយការណ៍របស់ក្រុមការងាររបស់ **ក្រុមហ៊ុន ខិនសាល់ចិនស៊ី ហ្វីម ផងដែរ** ។ ដូចនេះ ស្រុកមិនមានអ្វីលើកយកមកនិយាយច្រើនទៀតទេ តែសុំមាន

សំណូមពរចំនួន០៣គឺ (១) សុំឱ្យធ្វើការកាត់ចេញ នូវផ្ទៃដីដែលពាក់ព័ន្ធមួយចំនួនចេញ ដូចជាដីព្រៃសហគមន៍របស់ជនជាតិដើមភាគតិច(សួយ) ព្រៃតំណម (តំបន់គោល) ទីសក្ការៈ ទួលអ្នកតាជាដើម (២) ដោយតំបន់នោះជាតំបន់ធ្វើស្រែបឹង យើងគួរសិក្សាឱ្យបានច្បាស់ តើអាចមិនកាយព្រំបានទេ ព្រោះកាលណាកាយទៅធ្វើឱ្យប្រភពទឹកនៅតំបន់នោះហូរចុះទៅតាមប្រឡាយរបស់ក្រុមហ៊ុនអស់ ហើយធ្វើឱ្យប្រជាជនគ្មានទឹកសំរាប់ធ្វើស្រែទេ ម្យ៉ាងវិញទៀតការកាយព្រំដីរបស់ក្រុមហ៊ុនមានជំរៅជ្រៅបើមានសត្វពាហនៈ ធ្លាក់ចូលក្នុងប្រលាយក្រុមហ៊ុន នឹងធ្វើឱ្យងាប់បានព្រោះតាមការពិនិត្យរណ្តៅដែលកាយនោះអាចមានជំរៅ២-៣ម៉ែត្រ ហើយកន្លែងខ្លះក្រុមហ៊ុនបានធ្វើការកាយកាត់ផ្លូវចាស់ដែលប្រជាជនកំពុងតែប្រើប្រាស់ជាប្រចាំផងដែរ ដូចនេះគួរក្រុមហ៊ុនដាក់លូ ឬធ្វើស្ពាននៅកន្លែងផ្លូវនោះឱ្យពួកគាត់ធ្វើដំណើរវិញផង។ ចំពោះការឈូសឆាយនេះទៀតសោតកន្លងមកក្រុមហ៊ុនបានឈូសយកអាចម៍ដីទៅដាក់លើស្រែរបស់ពួកគាត់ ដែលកត្តានេះធ្វើឱ្យមានការ ខឹងសម្បាជាខ្លាំងពីប្រជាជនទាំងនោះ តែពួកគាត់មិនទាន់មានការប្រតិកម្មប្តឹងផ្តល់នៅឡើយទេ (៣) សំណូមពរសុំឱ្យមានការចុះទៅសិក្សាកំណត់ព្រំម្តងទៀត ថាគួរឈូសទុកគំលាតប៉ុន្មានម៉ែត្រពីព្រំស្រែរបស់ពួកគាត់ និងកំណត់ថាតើគ្រាន់តែធ្វើរបងបានទេ ឬចាំបាច់ត្រូវតែកាយប្រឡាយព្រំ ។ ស្រុកសុំធ្វើការគាំទ្រគំរោងផ្តល់ដីសម្បទានសេដ្ឋកិច្ច របស់រដ្ឋាភិបាលឱ្យទៅក្រុមហ៊ុនធ្វើការអភិវឌ្ឍន៍ ស្រុកយើងខ្ញុំមិនមានយោបល់ជំទាស់ទេ ព្រោះបើមានក្រុមហ៊ុនចូលទៅធ្វើការអភិវឌ្ឍន៍អាចមានការរីកចំរើន តែសុំធ្វើយ៉ាងណាដោះស្រាយនូវបញ្ហាដីពាក់ព័ន្ធនឹងប្រជាពលរដ្ឋឱ្យបានចប់ស្រេចបាច់សិនមុននឹងធ្វើការឈូសឆាយកំណត់ព្រំជៀសវាង កើតមានបញ្ហាទំនាស់ដីធ្លីដោះស្រាយមិនចេះចប់នោះ ដូច្នេះខ្ញុំមិនមានយោបល់អ្វីច្រើនទេ។ សូមសំណូមពររបស់ស្រុកសុំអោយក្រុមហ៊ុនដាក់បញ្ចូលនូវគំរោងផ្តល់ជាពូជដំណាំឱ្យប្រជាជនដាំសហការជាមួយក្រុមហ៊ុន ឱ្យបានគ្រប់គ្រួសារផង ហើយក្រុមហ៊ុនត្រូវបង្ហាញនូវការអភិវឌ្ឍន៍របស់ខ្លួន ដើម្បីអោយប្រជាជនបានឃើញ ចំពោះមុខនូវអ្វី ដែលក្រុមហ៊ុនបានធ្វើការសន្យារបស់ខ្លួនជាមួយប្រជាជន នឹងគោរពតាមកិច្ចសន្យារវាងក្រុមហ៊ុន និងក្រសួងបរិស្ថានផងដែរ ។

**ឯកឧត្តម កង ហ៊ាង** អភិបាលខេត្តៈ បើតាមការរាយការណ៍របស់ស្រុកថា ដីដែលក្រុមហ៊ុនស្នើសុំនេះគឺមានការពាក់ព័ន្ធដីធ្លីរបស់ប្រជាជន ដូចនេះយើងរួមគ្នាធ្វើយ៉ាងណាដោះស្រាយដើម្បីបញ្ចៀសនូវបញ្ហារវាង ប្រជាពលរដ្ឋ និងក្រុមហ៊ុន (ភ្លើងទានងាយនឹងពន្លត់បាន តែពន្លត់ភ្នំភ្លើងមិនងាយនឹងធ្វើបានឡើយ) ដូចនេះក្នុងមានអាជ្ញាធរសូមជួយសហការគ្នា ដើម្បីធ្វើការដោះស្រាយដែលប្រកបដោយសន្តិភាព ស្រុះស្រួលគ្នា ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋក្នុងតំបន់វិនិយោគ ទាំងនោះទទួលបានជីវភាពប្រសើរឡើង ។ ចំពោះការប្រជុំថ្ងៃនេះគឺមានសារៈសំខាន់ណាស់ក្នុងការចូលរួមយោបល់ របស់មន្ទីរជំនាញទាំងអស់ សុំចូលរួមយោប់ឱ្យបានច្រើនតាំងអស់គ្នាជៀសវាងមានបញ្ហានៅពេលក្រោយ ហើយតាមយោបល់ស្រុកឱរ៉ាល់ឃើញថា មិនមានយោបល់ជំទាស់ទេក្នុងគំរោងវិនិយោគរបស់ក្រុមហ៊ុននេះទេ ហើយចំពោះ ដីសម្បទាននេះអាចមានហើយលើដីព្រៃលើបរិស្ថានជាដើមនោះ ដូចនេះសុំខាងរដ្ឋបាលព្រៃឈើម្តង ។

Draft

លោក **ទូច សាលីន** នាយរងខ័ណរដ្ឋបាលព្រៃឈើ: ពាក់ព័ន្ធនឹងសំណើសុំដីសម្បទានសេដ្ឋកិច្ចនេះ ខាងរដ្ឋបាលព្រៃឈើ សុំធ្វើការឯកភាពចំពោះមតិរបស់ឯកឧត្តមអភិបាលខេត្ត ដែលបានលើកឡើងអំពីបញ្ហាពាក់ព័ន្ធការប្រមូលឈើ ដែលក្រុមហ៊ុនធ្វើការឈូសឆាយ ហើយគទុកនោះ គួរក្រុមហ៊ុនធ្វើលិខិតបើកផ្លូវស្នើសុំដឹកជញ្ជូនឈើទាំងនោះចេញ យកទៅប្រើប្រាស់ឱ្យអស់លទ្ធភាព ជៀសវាងទុកឈើទាំងនោះចោលនាំឱ្យមានការខាតបង់សំរាប់ចំណូលថវិការដ្ឋមួយចំនួនផងដែរ។ ចំពោះព្រៃឈើនៅខេត្តកំពង់ស្ពឺនេះមានលក្ខណៈជាព្រៃរល្បោះ៧០-៨០% ហើយព្រៃនៅក្នុងឃុំ ពីរនេះនៅមានសត្វព្រៃភាគច្រើនទន្សាយ ជ្រូកព្រៃ ឈ្លូស។ ហើយប្រព័ន្ធផ្លូវទឹកមិនមានច្រើនទេនៅតំបន់នោះ ទន្ទឹមនោះសុំពិនិត្យអំពីប្រភពទឹកនៅក្នុងតំបន់ដីនោះផងព្រោះប្រជាជនទាំងនោះភាគច្រើននៅប្រើប្រាស់ពីប្រភព ស្ទឹង អូរ និងបឹងនៅក្បែរៗនោះផងដែរ ។ នៅក្នុងនោះមានព្រៃសហគមន៍ជនជាតិដើមភាគតិចស្ទួយត្រូវធ្វើការថែរក្សា និងអភិរក្សទុកឱ្យពួកគាត់ផងដែរ ចំពោះរឿងមួយទៀតគឺទាក់ទងទៅនឹងមុខរបរប្រចាំថ្ងៃ របស់ពួកគាត់ពិសេសដើមជ័រច្បោះ និងឈើអូស នឹងឬស្សី ។ កន្លងមកម្ចាស់ដីសម្បទាន នៅពេលដែលបានសិទ្ធប្រទានដីទាំងនោះហើយគឺធ្វើការឈូសឆាយទាំងអស់មិន គិតពីរបរប្រចាំថ្ងៃរបស់ប្រជាជនទាំងនោះឡើយ។ ការផ្តល់ដីសម្បទាននេះឃើញថា មានតាំងពីអណត្តិមុនមកម្លេះ តែមិនឃើញមានក្រុមហ៊ុនណាធ្វើការដាំដុះនៅឡើយទេ មិនដឹងថា ទទួលបានសិទ្ធិស្របច្បាប់ហើយឬនៅនោះទេ។ តែចំពោះក្រុមហ៊ុន HLH នេះ ឃើញថាជាក្រុមហ៊ុនមួយឈានមុខគេក្នុងការដាំដុះមែន ខុសពីក្រុមហ៊ុនផ្សេងៗទៀត ទទួលបានសិទ្ធវិនិយោគហើយទុកដីនៅទំនេរ មិនព្រមធ្វើអ្វីទាល់តែសោះ ដូចនេះខ្ញុំគិតថាក្រុមហ៊ុននេះជា ក្រុមហ៊ុនវិនិយោគពិតប្រាកដមែន។ តែការសំរេចផ្តល់ដីសម្បទានទៅឱ្យក្រុមហ៊ុនណាមួយនោះ គួរឱ្យក្រុមការងាររដ្ឋបាលព្រៃឈើចុះសិក្សាឱ្យបានច្បាស់ ដើម្បីកំណត់ថា ព្រៃតំបន់ណាគួរ ទុកធ្វើការអភិរក្ស ហើយតំបន់ណាគួផ្តល់ ទៅឱ្យក្រុមហ៊ុនធ្វើការអភិវឌ្ឍន៍។ ជាចុងក្រោយចំពោះគំរោងផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះគឺ មិនមានការជំទាស់ទេ វាអាស្រ័យទៅខាងថ្នាក់លើជាអ្នកមានសិទ្ធិសំរេចចុះ ខាងជំនាញបានត្រឹមផ្តល់ជាយោបល់តែប៉ុណ្ណោះ ។

**ឯកឧត្តម កង ហ៊ាង** អភិបាលខេត្ត : បើតាមការរាយការណ៍របស់ក្រុមហ៊ន ចំពោះឈើដែលក្រុមហ៊ុនធ្វើការឈូសគរទុកនោះ ក្រុមហ៊ុនបានប្រាប់ថាទុកយកទៅធ្វើការសំងួតពោត ហើយខាងខេត្តក៏បានប្រាប់ទៅក្រុមហ៊ុនវិញថា បើទុកធ្វើការសំងួតទុកទៅ តែសុំថបើមានមួយផ្នែកណាដែលក្រុមហ៊ុនមិនងាចយកទៅធ្វើអ្វីបានទេនោះ សុំធ្វើការចែករំលែក ទៅឱ្យប្រជាជននៅក្នុងតំបន់នោះប្រើប្រាស់ខ្លះផង ទាំងនេះអាចកាត់បន្ថយការលួចចូលទៅកាប់ព្រៃតំបន់អភិរក្សបាន មួយចំនួនផងដែរ។

លោក **ឡាយ គឹមហៀង** ប្រធានមន្ទីរដែនដីខេត្តៈ យោងអនុក្រឹត្យ១១៨ កាគ្រប់គ្រងដីរដ្ឋត្រូវរៀបចំចំណាត់ថ្នាក់ ប្រភេទដីជាមុនសិន ហើយការផ្តល់ដីសម្បទានសេដ្ឋកិច្ច នោះទៀតសោតធ្វើឡើងដោយថ្នាក់ ខេត្តនិងថ្នាក់ជាតិទៅតាមកំរិតនៃទុនវិនិយោគ និងទំហំដី ដើម្បផ្តល់ដីសម្បទានសេដ្ឋកិច្ចឱ្យមានភាពរលូន ជៀសវាង

Draft

អ្នកវិនិយោគមានភាពចុញទ្រាន់គួរគួរថ្នាក់ជាតិ សហការណ៍ជាមួយក្រុមការងារថ្នាក់ខេត្ត និងជំនាញ ពាក់ព័ន្ធចុះធ្វើការសិក្សារួមគ្នាដើម្បីធ្វើការកំណត់នូវព្រំដីមួយមានភាពជាក់លាក់ ថាតំបន់ដែលគ្រោងនឹងផ្តល់ ទៅឱ្យក្រុមហ៊ុន នោះមានពាក់ព័ន្ធនឹងភូមិប្រជាជន ដើមភាគតិចដែរឬអត់? តែចំពោះគំរោងស្នើសុំដីរបស់ HLH នេះខាងមន្ទីរដែនដីមិនបានដឹងទេ ព្រោះក្រុមហ៊ុនមិនបានធ្វើការសហការជាមួយតែ ទៅទាក់ទងតែជាមួយបរិស្ថាន បើតាមខ្ញុំដឹងនៅក្នុងតំបន់ដីដែលក្រុមហ៊ុនធ្វើការស្នើរសុំនោះ មានពាក់ព័ន្ធនឹងតំបន់ទីសក្ការៈរបស់ជនជាតិដើមភាគតិចសួយដែរ តែក៏មិនបានដឹងពីការពាក់ព័ន្ធដីស្រែប៉ុន្មានហិកតាចំការប៉ុន្មានហិកតា? ផ្ទះប៉ុន្មានគ្រួសារ ? ដូចនេះគួរចុះ ធ្វើអត្តសញ្ញាណកម្មលំអិតដោយធ្វើសំភាសជាមួយប្រជាពលរដ្ឋផ្ទាល់ ហើយត្រូវពិនិត្យវាយតំលៃទៅលើទីតាំង ដីជាក់ស្តែងតើមានដាំដំណាំអ្វីខ្លះ ? ជូនកាលពួកគាត់នាំគ្នាចូលទៅ បោះបង្គោលក្នុងព្រៃហើយ ស្រែកថាជាដី របស់ពួកគាត់ដែរនោះគឺពិតជាមិនត្រឹមត្រូវទេ ត្រូវប្រមូលដីនោះមករក្សាជាដីរដ្ឋវិញ។ ចំពោះដីដែលខេត្តបាន ផ្តល់សិទ្ធិវិនិយោគទៅឱ្យក្រុមហ៊ុនមួយចំនួនកន្លងមក ហើយក្រុមហ៊ុនបានលើកសំណើរ ទៅក្រសួងកសិកម្មនោះ រហូតមកទល់នឹងពេលនេះនូវមិនទាន់ដឹងបានទទួលអាជ្ញាប័ណប៉ុន្មានហើយដែរ តែក្រុមហ៊ុនទាំងនោះតែមិនទាន់ មានធ្វើការអភិវឌ្ឍន៍អ្វីនោះទេ ប្រហែលក្រុមហ៊ុនទាំងនោះមិនទាន់ទទួលបានច្បាប់គ្រប់គ្រាន់នៅឡើយទេ ហើយមាន ក្រុមហ៊ុនមួយចំនួនក៏កំពុងតែដើរកមួយសំរាប់លក់បន្តផងដែរ ជាចុងក្រោយទស្សនះរបស់ខ្ញុំសំឯកភាពតាមមតិ របស់មេព្រៃ និងឧស្សហកម្មក៏សូមឯកភាពតាមមតិរបស់ស្រុកនិងក្រុមការងារសិក្សាវាយតំលៃផងដែរសូមអរគុណ។

លោក **គួន ហេង** ប្រធានមន្ទីរបរិស្ថានៈ គំរោងស្នើសុំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន HLH នេះមានចំនួនរហូតដល់ទៅជិត១ម៉ឺនហិកតានេះ ឃើញថាមានទំហំធំណាស់ ដូចនេះអាចនឹងមានផលប៉ះពាល់ជាច្រើនដល់បរិស្ថាន ប្រសិនបើមិនមានផែនការគ្រប់គ្រងបរិស្ថានឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ទេនោះ តែការចូលរួមរបស់ខ្ញុំនៅថ្ងៃនេះមិនមានធ្វើច្រើនទេ គឺខ្ញុំសូមធ្វើការចាប់អារម្មណ៍ទៅលើចំណុច៣សំខាន់ៗគឺ (១) ធនធានធម្មជាតិ នេះគឺសំដៅទៅលើព្រៃឈើ សត្វព្រៃ និងប្រភេទ ជីវៈចំរុះផ្សេងៗជាដើម ដូចនេះចំពោះ តំបន់ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ដីមាត់ស្ទឹង មាត់ព្រែក អូរ និងភ្នំគួរធ្វើការរក្សាទុកព្រោះកន្លែងទាំងនោះជា កន្លែងជ្រកពួនស្នាក់អាស្រ័យរបស់ពពួកសត្វព្រៃ ។ (២) អំពីបរិស្ថានមនុស្ស ត្រូវផ្តោតសំខាន់ទៅលើបញ្ហាសុខភាពសាធារណៈ និងការរស់នៅរបស់ប្រជាជននៅ ក្នុងតំបន់នៃគំរោង ដែលប្រជាជនក្រីក្រទាំងនោះកំពុងរស់ នៅក្នុងស្ថានភាពយ៉ាប់យ៉ឺន និងកំពុងប្រើប្រាស់ ធនធានធម្មជាតិដែលនៅជុំវិញខ្លួនរបស់ពួកគាត់ ដែលពួកគាត់ រស់នៅសង្ឃឹមទៅដីស្រែចំការ ដែលកំពុងបង្កបង្កើនផលតាំងនោះ។ (៣)បញ្ហាសង្គម និងវប្បធម៌ៈ ត្រូវគិត អំពីបញ្ហាប៉ះទៅលើទីសក្ការៈមួយចំនួនរបស់ជនជាតិភាគតិចសួយ គួរធ្វើការ សិក្សាឱ្យបានច្បាស់លាស់ពីចំណុចប៉ះពាល់ លើទីសក្ការៈទាំងនោះដែលអាចនឹងមានការប៉ះពាល់ខ្លាំងដល់ប្រពៃណី និងវប្បធម៌របស់ពួកគាត់។ មុនពេល ដែលក្រុមហ៊ុនទទួលបានសិទ្ធិប្រទានពីរាជរដ្ឋាភិបាល ចាំបាច់ត្រូវចុះធ្វើសិក្សាវាយតំលៃ

ហេតុប៉ះពាល់បរិស្ថាន និងប្រភពទឹកនៅក្នុងទីតាំងដីទាំងនោះ ព្រមទាំងប្រពៃណីយ៍ជនជាតិដើមភាគតិច និងមុខរបររបស់ពួកគាត់ ។ល។

លោក **យឹម ណាន** តំណាងមន្ទីរកសិកម្ម: ខ្ញុំបាទសូមចូលរួមមតិលើពីរចំណុច យោងលើគោលបំណងក្រុមការងារវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះ (១) ទាក់ទង និងលិខិតបទដ្ឋាន ពិសេសមានសៀវភៅផែនការមេដែលមានចុះហត្ថលេខាដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ នេះជាវិធីសាស្រ្ត នៃការអនុគ្គនីគំរោងឈូសឆាយដីទាំងនោះបាន ។ (២) ទាក់ទងនឹងការកំណត់ព្រំ ហើយពាក់ព័ន្ធដីធ្លីរបស់ប្រជាពលរដ្ឋប៉ះពាល់ និងដីកសិកម្ម របស់ពួកគាត់ទាំងនោះផងដែរ ចំពោះការកាយព្រំនេះបើកាយទៅជ្រៅពេកនោះ ធ្វើឱ្យអស់ទឹកធ្វើកសិកម្មរបស់ពួកគាត់ ដោយទឹកទាំងនោះហូរចូលទៅក្នុងប្រឡាយក្រុមហ៊ុននោះអស់ ។ ហើយនៅក្នុងការប្រជុំនៅពេលនេះ មិនឃើញបង្ហាញតែលើកិរិតនៃការ ប៉ះពាល់ទៅលើបរិស្ថាន ព្រៃឈើ និងកិរិតនៃការប៉ះពាល់ទៅលើសង្គមនៅតំបន់ស្នើសុំរបស់ក្រុមហ៊ុន។ សូមបង្ហាញ ថាតើការប៉ះពាល់ទៅលើបរិស្ថាន មានផលប៉ះពាល់ទៅលើអ្វីខ្លះ ដូចជាការប៉ះពាល់ទៅលើជំរកសត្វព្រៃឬការ ប៉ះពាល់ទៅលើព្រៃដែលត្រូវរក្សាទុកជាដើម។ ប៉ុន្តែបើតាមការពិនិត្យមើលទៅលើរូបភាពដែលបានបង្ហាញឃើញថា ជាប្រភេទព្រៃសោង ពាក់កណ្តាលស្រោង និងព្រៃរល្បោះ ដូច្នេះចំពោះព្រៃរល្បោះ មិនមានបញ្ហា ទេចំពោះធនធានអេកូឡូស៊ីនៅតំបន់នោះ តែចំពោះ ជាប្រភេទព្រៃសោង ពាក់កណ្តាលស្រោងអាចមានការ ប៉ះពាល់តិចឬច្រើនមិនខាន ។ ទន្ទឹមនោះសុំឱ្យក្រុមអ្នកសិក្សាវាយតំលើផលប៉ះពាល់បរិស្ថាន និងសង្គមលើក ឡើងពីវិធីសាស្រ្តក្នុងសិក្សា ដើម្បីធ្វើការវាយ តំលៃនូវធនធានព្រៃឈើក្នុងតំបន់នេះជាព្រៃស្រោង ឬជាព្រៃរល្បោះឱ្យបានជាក់លាក់ជាងនេះបន្តិច។ ដូច្នេះសុំអោយខាងអ្នកជំនាញបច្ចេកទេសធ្វើការបង្ហាញ ពីវិធីសាស្រ្តក្នុង ការចុះសិក្សាដែលអាចរក បាននូវពតិមានពិតប្រាកដ ដែលយើងងាយស្រួលក្នុងការដោះស្រាយ ជៀសវាងមាន បញ្ហាពេលផ្តល់អោយក្រុមហ៊ុន។ ដូច្នេះបើក្រុមការងារដែលមានជំនាញមានវិធីសាស្រ្តអ្វីក្នុងការចុះសិក្សាដើម្បី កំណត់អំពីហេតុប៉ះ ពាល់បានច្បាស់លាស់ទាំងបញ្ហាបរិស្ថាន និងសេដ្ឋកិច្ចសង្គម? ដើម្បីរកឃើញនូវពតិមានពិត ជាក់ស្តែងទាំងនោះ តើយើងមានវិធីសាស្រ្តអ្វីខ្លះ? យើងអាចដឹងហើយ ការអភិវឌ្ឍន៍តែងមានចំណុចវិជ្ជមាន និងអវិជ្ជមាន ដូចនេះត្រូវចូលរួមដោះស្រាយនូវចំណុចអវិជ្ជមានឱ្យបានអស់នោះជាការល្អសំរាប់អ្នកវិនិយោគ ជៀសវាងមាន បញ្ហាកើតមានច្រើនធ្វើឱ្យអ្នកវិនិយោគមានការធុញទ្រាន់ និងរាថយធ្វើឱ្យគំរោងការអភិវឌ្ឍន៍ មានសន្ទុះយឺត ដែលធ្វើឱ្យប្រជាពលរដ្ឋមានជីវភាពកាន់តែលំបាកទៅៗ។

**លោក ចាន់ វណ្ណា** ក្រុមការងារ GCF: ខ្ញុំសូមអនុញ្ញាតពីឯកឧត្តមប្រធាន សុំធ្វើការបញ្ជាក់បន្តិចថា Green Consultancy Firm យើងខ្ញុំ មានអ្នកជំនាញជាច្រើនក្រុម·(១) ក្រុមសិក្សាបរិស្ថាន ដោយក្រុមនេះចុះសិក្សាផ្ទាល់នៅក្នុងតំបន់ដីព្រៃដែលក្រុមហ៊ុនបានស្នើសុំ ដោយផ្អែកលើផែនទីដីដែលក្រុមហ៊ុនផ្តល់ឱ្យក្រុមការ

Draft

ងារយើងខ្ញុំ ដោយធ្វើការអង្កេត ទៅលើប្រភេទព្រៃ ថតរូបភាពព្រៃឈើ សិក្សាពីប្រភេទដី វាយតំលៃពីគំរបព្រៃ និងសុខភាពរបស់ព្រៃ និងរាប់ចំនួនដើមឈើតាម លំដាប់ថ្នាក់អង្កត់ផ្ចិតក្នុងមួយហិកតា ដោយគិតរាប់តាំងពីដើមឈើដែលមានអង្កត់ផ្ចិត៥-៩ស.ម ពី១០-២៩ ស.ម និងចាប់ពី ៣០ស.ម ឡើងទៅ។ ចំណុចដែលចុះទៅធ្វើការសិក្សាប្រមូល ទិន្នន័យទាំងនោះមានបង្ហាញ ពីចំណុចនិយាមកាច្បាស់លាស់ដែល អាចឱ្យក្រុមការងារផ្សេងៗចុះធ្វើការផ្ទៀងផ្ទាត់បាននៅពេលមានការ សង្ស័យថាពតិមានទាំងនោះមិនពិត ។ (២) ក្រុមការងារសិក្សាផ្នែកសង្គម ក្រុមនេះចុះទៅធ្វើការទំនាក់ទំនងសាកសួរពតិមាន ពីសំណាក់អាជ្ញាធរមូលដ្ឋាន ដែលពាក់ព័ន្ធ និងទីតាំងដីដែលក្រុមហ៊ុនស្នើសុំ ព្រមទាំងចុះជួបសួរពតិមានផ្ទាល់ពីប្រជាជននៅក្នុងតំបន់ ពាក់ព័ន្ធ ដូចជាសួរអំពីដីស្រែ ចំការរបស់ពួកគាត់ ការអាស្រ័យផល-អនុផលព្រៃឈើនៅតំបន់នោះ ទន្ទឹមនោះ ក៏ធ្វើការសិក្សាទៅលើសេដ្ឋកិច្ចនៅតាមគ្រួសារនិមួយៗផងដែរ ក្រៅពីនោះក្រុមការងារនេះបានធ្វើអង្កេតទៅលើ សេវាសារធារណៈផ្សេងៗដូចជា ផ្លូវថ្នល់ សាលារៀន មណ្ឌលសុខភាព អណ្តូងទឹកស្អាតជាដើម ។ល។ (៣) ការពិនិត្យ និងវាយតំលៃស្ថានភាពធនធានព្រៃឈើលើរូបភាពថតពីអាកាស ដោយប្រើ Paramotor ដើម្បីពិនិត្យ និងវាយតំលៃអំពីគំរបព្រៃ និងស្ថានភាពធនធានជាក់ស្តែងក្នុងពេលបច្ចុប្បន្ន ក្រុមការងារបានធ្វើការហោះហើរ ដោយប្រើឧបករណ៍ Paramotor ដើម្បីថតយករូបពិតពីអាកាស ហើយធ្វើការប្រៀបធៀបជាមួយនឹង រូបភាពប្រើប្រាស់ដីធ្លី និងគំរបព្រៃឆ្នាំ២០០៦ និងការធ្វើអង្កេតអេកូឡូស៊ី ជាក់ស្តែងនៅលើទីវាល។ ការហោះហើរតាមគន្លងដូចមានបង្ហាញក្នុងផែនទីវិស្សុតកម្មគន្លងហោះហើរនិងទីតាំងរូបថត ដោយថតយក រូបភាពដែលមាន Format: Geo_tif និង កំរិតភាពច្បាស់សម្រាប់វត្ថុមានទំហំពី ៤០ស.មឡើង ដោយថតជាមួយនឹងប្រព័ន្ធកូអ័រដោនេ និយាមកា Datum: WGS-84 និង Spheroid: WGS-84 ស្ថិតក្នុងរយៈកំពស់ ៧០០-១២០០ម៉ែត្រ ហើយនៅលើគន្លងហោះ ហើរចំងាយមួយដែលអាចយកជាការ បានអាចពី ២០-៣០គ.ម ដោយបានថតយករូបភាពចំនួនពី ១៥-២៥កន្លែង ដែលគ្របដណ្តប់លើផ្ទៃដីតិចបំផុត ចំនួន ១៣-៣០ភាគរយនៃផ្ទៃដីសម្បទានសរុប។ ក្រៅពីរូបភាពដែលមាន Geo-Reference ក្រុមហោះហើរ បានថតយករូបភាព Eye-View (ជារូបភាពដែលគ្មាន Geo-Reference) ចំនួន៦-១៥ កន្លែងទៀតដូច ដែលមានបង្ហាញក្នុងផែនទីវិសុត្យកម្ម។ តាមរយៈរូបភាព Photographical Maps ទាំងនោះបង្ហាញអោយ ឃើញថា គំរបព្រៃនិងធនធានព្រៃឈើមានលក្ខណៈរេចរិលខ្លាំង ឬក៏នៅល្អ អាស្រ័យដោយរូបភាពដែលយើង ថតបានពីដីនៅទូទាំងដែនសម្បទានទាំងមូល ទោះបីជាព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោងក្តី ក៏យើងអាច វាយតំលៃបាននៃការទទួលរងការរំខានរបស់ព្រៃទាំងនោះដែរ ។ ទន្ទឹមនោះ តាមរយៈការវិភាគលើរូបភាព Indexes បង្ហាញថា អំពីស្ថាសនភាពនៅតាមដង ព្រែក អូរ និងដៃនាទារបស់ តំបន់ទ្រនាប់សងខាង និងទំនាប ដីសើមរបស់ប្រព័ន្ធព្រែកទាំងនោះមានលក្ខណៈប្រសើរឬអត់ ដោយមានគំរបបៃតងស្រស់ ឬជ្រុះស្លឹកអស់នៅ រដូវប្រាំង។

Draft

លោក **វ៉ាន់ សុខា** អគ្គលេខាធិការៈ ចំពោះការជួបប្រជុំពិភាក្សាគ្នានៅថ្ងៃនេះ គ្រាន់តែជាក្រុមហ៊ុនមួយដែលក្រុមហ៊ុន HLH ឱ្យចុះមកធ្វើការសិក្សា វាយតំលៃហេតុប៉ះពាល់បរិស្ថាន និង សង្គម ដើម្បធ្វើយ៉ាងណាដោះស្រាយអំពីផលប៉ះពាល់បរិស្ថាន និងសង្គម ដូចនេះ ខ្ញុំសូមសុំចូលរួមមានយោបល់ផងដែរចំពោះ គំរោងស្នើសុំដីសម្បទាន នេះនឹងសុំធ្វើការ ចុះកំណត់ធ្វើអត្តសញ្ញាណកម្មដីរដ្ឋនេះ ដែលជាវិធីសាស្ត្រ មួយធ្វើឱ្យច្បាស់លាស់លើដីពាក់ព័ន្ធនិងដីរដ្ឋក្តី ដីដីប្រជាពលរដ្ឋក្តី ជាក់ស្តែងដោយសារតែមិនបានចុះសិក្សា និងធ្វើអត្តសញ្ញាណកម្មដីធ្លីមិនច្បាស់លាស់នោះ ទើបបច្ចុប្បន្នកំពុងមានភាពចំរូងចំរាស់យ៉ាងខ្លាំង អត្តសញ្ញាណកម្មនេះ ត្រូវតែធ្វើឱ្យច្បាស់លាស់ និងលំអិត បំផុតថា តើដីដែលប្រជាជនចូលទៅរស់នៅទីនោះចាប់ពីឆ្នាំណា? ហើយដី ដែលពួកគាត់កំពុងតែធ្វើការគ្រៀវ ដើមឈើចាប់យកដីរដ្ឋនោះពីពេលណា? ត្រូវប្រាប់ពួកគាត់ឱ្យច្បាស់ថាត្រូវ មានទោស។ ខ្ញុំសូមធ្វើការឯកភាពតិរបស់អភិបាលស្រុក ថាមុន នឹងធ្វើការឈូសឆាយត្រូវមានការជួបប្រជុំ និងចុះទៅកំណត់ព្រំទាំងអស់គ្នា ជៀសវាងបង្កឱ្យមានជំលោះរវាងប្រជាជន និងក្រុមហ៊ុន ហើយការសំរេចផ្តល់ដីឱ្យក្រុមហ៊ុនទៀតសោត បើដីមានការជាន់គ្នាជាមួយដីប្រជាពលរដ្ឋ ឬទីសក្ការៈរបស់ពួកគាត់នោះ ត្រូវធ្វើការដោះស្រាយប្រកបដោយការយកយល់គ្នាសិន។ ចំពោះការកាយព្រំសុំឱ្យធ្វើការកាយរាក់បានហើយឬក៏ ធ្វើរបងវិញបើសិនជាអាចធ្វើទៅបានហើយក្រុមហ៊ុនត្រូវគោរពកិច្ចសន្យាដែលបានធ្វើជាមួយក្រសួងបរិស្ថាន ។ ចំពោះទាក់ទងនឹងអនុផលព្រៃឈើនោះក្រុមហ៊ុនមិនអាចធ្វើការប្រមូលអស់នោះទេ គួរចែករំលែកខ្លះទៅ ប្រជាពលរដ្ឋនៅក្នុងតំបន់នោះប្រមូលនិងប្រើប្រាស់ ជៀសវាងគរទុកនិងដុតចោល។ ម្យ៉ាងវិញទៀត ពិនិត្យទៅលើការដាំដំណាំពោតនេះការប្រើប្រាស់កម្មករគឺមានពីរដំណាក់កាលប៉ុណ្ណោះ ទីមួយប្រើពលករនៅពេលដែល ឈូសឆាយរៀបចំដី ហើយនិងទីពរប្រើនៅពេលកាច់ប្រមូលផល ចំណែកការងារប្រឡេះគ្រាប់ ឬការងារ ផ្សេងៗនោះមិនចាំបាច់ប្រើកម្មករទៀតទេ ព្រោះក្រុមហ៊ុនប្រើបច្ចេកទេសពាក់កណ្តាលស្វ័យប្រវត្តិ ដូចនេះប្រើ ប្រាស់កម្មករមានរយៈពេលខ្លីណាស់ខុសពីដំណាំកៅស៊ូ។ ចំពោះគំរោងក្រុមហ៊ុននេះយើងគាំទ្រ ថាពិតជាក្រុមហ៊ុនមួយដែលមានដើមទុន និងធ្វើពិតប្រាកដមែន ។

**ឯកឧត្តម ទូច សារុន អភិបាលរងខេត្ត** : ខ្ញុំមានការចាប់អារម្មណ៍ដែរ ទៅលើគំរោងស្នើរសុំដីសម្បទានសេដ្ឋកិច្ចនេះ ព្រោះថាការផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅតំបន់នេះ គឺមិនមែនមានប៉ះពាល់ទៅលើតែព្រៃឈើបរិស្ថាន និងប្រជាពលរដ្ឋនោះទេ ខ្ញុំគិតថាវាអាចមានប៉ះពាល់ និងវិស័យទេសចរផងដែរ ការរកចំណូលចូលថវិកាជាតិ មិនសំខាន់ទៅលើចំណូលពីវិស័យកសិ -ឧស្សាហកម្មទាំងស្រុងដែរ ដូចនេះសុំឱ្យមានការចុះពិនិត្យពីលទ្ធភាពដីព្រៃឈើ បរិស្ថាននៅតំបន់នោះឱ្យបានច្បាស់លាស់ ដូចជាតំបន់ដែលមានសក្តនុពលអាចបង្កើតជាតំបន់ទេសចរធម្មជាតិ តំបន់សិក្សាស្រាវជ្រាវជីវចំរុះ ហើយចំពោះតំបន់ដែលមានជានជាតិដើម ភាគតិចរស់នៅគួររៀបចំអភិរក្ស ភូមិករ ប្រពៃណីយ៏ ទំនៀមទំលាប់ប្រែក្លាយតំបន់ទាំងនោះឱ្យក្លាយជាតំបន់ទេសចរណ៍ និងបង្កើនចំណូលថវិកាជាតិ និងលើកស្ទួយភាពក្រីក្ររបស់ពួកគាត់នៅក្នុងតំបន់ផងដែរ។ ដូចនេះគួរគិតគូរឱ្យបាន



Draft

ល្អិតល្អន់នឹងគ្រប់ជ្រុងជ្រោយ។ ដូចនេះ សំណូមពរទៅស្រុក ឃុំ ភូមិ សុំចូលរួមឱ្យបានសកម្មក្នុងការចុះកំណត់ទីតាំងស្នើសុំដីសម្បទានសេដ្ឋកិច្ចនេះ តាមទស្សនៈខ្ញុំផ្ទាល់សុំឯកភាព ចំពោះគំរោងផ្តល់ដីសម្បទានសេដ្ឋកិច្ចទាំងអស់ ក្នុងការប្រែក្លាយដីព្រៃដែល រេចរិលទាំងនោះ ដើម្បីទាញយកនូវចំណូលថវិកាចូលរដ្ឋ ហើយធ្វើការគ្រប់គ្រង និងប្រើប្រាស់ដីរដ្ឋដែលទំនេរ ទាំងនោះឱ្យត្រូវតាមគោលដៅបានល្អ ដែលចំណេញទាំងរដ្ឋ ហើយស្តាគំរបព្រៃបៃតងឡើងវិញបានល្អទៀត។ សូមគាំទ្រទាំងស្រុងចំពោះមតិរបស់ឯកឧត្តមអភិបាលខេត្ត ដែលតែងតែយកចិត្តទុកដាក់លើបញ្ហានេះជាខ្លាំង ពិសេស(១)ពាក់ព័ន្ធនិងការសហការណ៏ រវាងអាជ្ញធរ និងក្រុមហ៊ុនបើមិនបានសហការណ៏គ្នាល្អទេគឺមានការពិបាកណាស់ក្នុងការដោះស្រាយ ហើយ(២)ក្រុមហ៊ុនត្រូវយកចិត្តទុកដាក់មតិសាធារណៈរបស់សហគមន៍ក្នុងតំបន់ (៣)ក្រុមហ៊ុនត្រូវចូលរួមក្នុងការថែរក្សានូវប្រពៃណីយ៍ទំនៀមទំលាប់របស់សហគមន៍ជនជាតិដើមភាគតិច (៤) ធានាមិនប៉ះពាល់លើដីស្រែចំការ និងភូមិករ របស់ពូកគាត់។ ជាវិធាន នៅពេលដែលក្រុមហ៊ុនទទួលបានសិទ្ធិប្រទានហើយ សុំឱ្យមានការសហការណ៏ចាមូអាជ្ញធរមានសមត្ថកិច្ចចូលរួមផង ដើម្បីជៀសវាងទំនាស់ និងងាយស្រួលក្នុងការដោះស្រាយសម្របសម្រួល។ (៥) ចំពោះការកាយព្រំ ត្រូវពិចារណាថា គួកាយព្រំនៅកន្លែងណា ហើយគួរធ្វើរបងនៅកន្លែងណា? ជាចុងក្រោយការជួបប្រជុំនៅ ថ្ងៃនេះគឺយើងចូលរួមដោះស្រាយធ្វើយ៉ាងនាជំរុញឱ្យក្រុមហ៊ុនអាចដំណើរការទៅមុខបានរលូនជៀសវាង ការស្មុគស្មាញ ដូចនេះសុំអញ្ជើញឯកឧត្តមអភិបាលខេត្តធ្វើការសរុបមតិ។

លោក **ទូច សាលីន** នាយរងខ័ណរដ្ឋបាលព្រៃឈើ: សុំចូលរួមយោបល់បន្ថែម ចំពោះទស្សនៈនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះ(១) គាំទ្រសូមស្វាគមន៏ជានិច្ចគ្រប់ក្រុមហ៊ុនទាំងអស់ទាំងក្នុងនិងក្រៅស្រុក ។(២)គាំទ្រមតិសុរិយោដី ក្នុងការចុះធ្វើអត្តសញ្ញាណកម្មដីធ្លួ(៣) បើក្រុមហ៊ុនទទួលបានសិទ្ធិគ្រប់គ្រងហើយ សុំអនុវត្តឱ្យបានឆាប់រហ័សជៀស វាងទុកដីចោលមិនធ្វើអ្វីសោះ។ (៤) រឿងហេតុប៉ះពាល់និងព្រៃឈើពេលចុះសិក្សា សុំឱ្យមានការចូលរួមពីមេព្រៃផង ធ្វើយ៉ាងនេះទើបមានការច្បាស់លាស់។ (៥) ការព្រួយបារម្ភធំជាងគេគឺការប៉ះពាល់ជាមួយដីភូមិករស្រែចំការ ប្រជាពលរដ្ឋ ពិសេសភូមិជនជាតិដើមភាគតិច បញ្ហានេះត្រូវសិក្សាឱ្យបានច្បាស់។

**លោក ចាន់ វណ្ណា :** ចំពោះគោលការនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល គឺធ្វើយ៉ាងផ្តល់នូវកាលានុវត្តភាពការងារថ្មីៗ ដល់ប្រជាពលរដ្ឋរស់នៅតំបន់ក្បែៗនោះ និងប្រជាជន ពីតំបន់ដទៃទៀត។ ដែលនឹងធ្វើអោយជីវភាពរស់នៅរបស់ពូកគាត់មាន លក្ខណៈល្អប្រសើរជាងមុន ហើយការកើនឡើងនូវកំរិតជីវភាពរស់នៅនេះ នឹងផ្តល់អោយពួកគាត់នូវជំរើសផ្សេងៗទៀតក្នុង ការប្រកបរបរចិញ្ចឹមជីវិត។ ឧទាហរណ៏ពួកគាត់អាចផ្លាស់ប្តូរការរស់នៅរបស់គាត់ពីការប្រាស្រ័យ លើធនធានធម្មជាតិ ទៅជាមុខរបរផ្សេងៗទៀតមានដូចជា: ការបំរើ ការងារជាបុគ្គលិក-កម្មករនៅ ក្នុងគំរោងរបស់ក្រុមហ៊ុន ឬតាមកសិដ្ឋាន និង ឧស្សាហកម្មកែច្នៃជាដើម ថ្វីត្បិតតែដំបូងហាក់បីដូចជាមានការពិបាកចំពោះពួកគាត់ក៏ពិតមែនតែនៅពេលដែលមានគ្រួសារ

Draft

គំរូនៅក្នុងភូមិរបស់ពួកគាត់មានជីវភាពធូធារនោះគាត់ និងធ្វើតាមគ្នាមិនខាន ខ្ញុំជឿថាអញ្ចឹង។ (២)ការអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្មនៅក្នុងតំបន់នោះនឹងនាំអោយមានការជំរុញសកម្មនូវ ចរន្តសេដ្ឋកិច្ច នៅក្នុងភូមិ ឃុំ ស្រុក និង ខេត្ត តាមរយៈការបង្កើតអោយនូវសេចក្តីត្រូវការស្បៀង (ស្រូវអង្ករ បន្លែបង្ការ និងត្រីសាច់ផ្សេងៗ) និងការផលិតស្បៀងដើម្បីផ្គត់ផ្គង់។ (៣) ធ្វើអោយប្រជាជនក្នុងតំបន់មានការអភិវឌ្ឍន៍ផ្នែកផ្គត់គំនិតតាមរយៈការផ្លាស់ប្តូរបទពិសោធន៏ ការងារពីសំណាក់មនុស្សចំណូលថ្មី ឬក៏ការទទួលបានការបណ្តុះបណ្តាលផ្នែកជំនាញបច្ចេកទេសកសិកម្មផ្សេងៗពីសំណាក់ក្រុមហ៊ុន។ (៤)ផ្តល់ឱកាសអោយ ប្រជាពលរដ្ឋក្នុងសហគមន៏ទទួលបាន នូវសេវាសាធារណៈពេញលេញដូចជាៈ សេវាអប់រំ (ក្មេងៗមានឱកាស ទៅសាលារៀនគ្រប់ៗគ្នា) សេវាសុខភាព សេវាគមនាគមន៏ ថាមពល អគ្គីសនី និងទឹកស្អាតជាដើម។ ហើយគំរោងផ្តល់ដីសម្បទាននេះផងដែរ គឺរាជរដ្ឋាភីបាលភានធ្វើការកាត់ចេញនូវតំបន់អធិរក្សមួយចំនួនដូចជា តំបន់ព្រៃសហគមន៏ជាតិដើមភាគតិច តំបន់ព្រៃតំណម មានវាលកប់ខោច កន្លែងគោរពបូជា ព្រៃអ្នកតាជាដើម ទន្ទឹមនោះព្រៃស្រោងព្រៃពាក់កណ្តាលស្រោង និងតំបន់ត្រនាប់ការពារទីជំរាល និងតំបន់ត្រនាប់មាត់ស្ទឹង អូរ ត្រពាំង បឹងក៏ត្រូវធ្វើការកាត់ចេញ ហើយក៏មានការត្រៀមទុកនូវដីបំរុង(ដីសម្បទានសង្គមកិច្ច) សំរាប់កំណើនប្រជាជននៅពេលខាងមុខផងដែរ ធ្វើយ៉ាងនេះគឺក្នុងគោលបំណងកាត់បន្ថយនូវទំនាស់រវាងប្រជាពលរដ្ឋក្នុងតំបន់ពាក់ព័ន្ធនិងវិនិយោគគិន។ ហើយក្រោយពីទទួលបាននូវសិទ្ធិប្រទានពីរាជរដ្ឋាភិបាលហើយក្រុមហ៊ុនត្រូវរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធសាថារណៈជាច្រើនក្នុងការចូលរួមក្នុងយុទ្ធសាស្រ្តស្តារ និងកាត់បន្ថយភាពក្រីក្រនៅជនបទនោះតែម្តង។

**ឯកឧត្តម កង ហ៊ាង** អភិបាលខេត្តកំពង់ស្ពឺៈ ក្រោយពីធ្វើការពិភាក្សាគ្នា និងស្តាប់យោបល់ ជំនាញដែលបានចូលរួមក្នុងឱកាសនេះក្នុងនាមខ្ញុំជាអភិបាលទទួលបន្ទុកការងារនេះ សូមសំណូនពរដូចខាង ក្រោមៈ

១-សុំឱ្យក្រុមការងារធ្វើការកត់ត្រា នូវអ្វីដែលអង្គប្រជុំបានលើកឡើងនៅពេលនោះ ដាក់បញ្ចូលទៅ ក្នុងរបាយការណ៍សិក្សាពេញលេញរបស់ក្រុមងការងារ។

២-ចំពោះរបាយការណ៏សិក្សាហេតុប៉ះពាល់បរិស្ថានរបស់ក្រុមហ៊ុនផ្សេងៗ មិនដែលបានធ្វើរបាយការណ៍ជូនខេត្តទេកន្លងមក ។

៣- ដើម្បីឱ្យរបាយការណ៍នេះមានលក្ខណៈល្អប្រសើរ ដើម្បីឱ្យក្រុមហ៊ុនទទួលបានសិទ្ធិវិនិយោគលើទី តាំងដីនោះពេលចុះទៅអនុវត្តនឹគ្មានការស្មុគស្មាញ ក្រុមហ៊ុនចាំបាច់ត្រូវមានផែនការមេ ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម។

៤-ទាក់ទង និងការូសឆាយ ពេលប៉ះពាល់ និងដីស្រែរបស់ប្រជាពលរដ្ឋត្រូវធ្វើការដោះស្រាយ ជាមួយប្រជាជនឱ្យបានស្រុះស្រួលគ្នា ដែលជាការសំខាន់ ក្រុមហ៊ុនពេលចុះសិក្សាត្រូវសហការណ៍ជាមួយអាជ្ញាធរពាក់ព័ន្ធឱ្យបានល្អ។ ព្រោះកិច្ចសន្យាវិនិយោគនេះមានរយៈពេលរហូតដល់ទៅ៧០ឆ្នាំឯណោះ ហើយម្យ៉ាងទៀតរាស្រ្តនៅស្រុកឱរ៉ាល់នេះមិនពិបាកនិយាយគ្នាទេ ។

(៥) - ត្រូវពិនិត្យលទ្ធភាពឱ្យបានច្បាស់ថាកន្លែងណាគួរកាយព្រំ ហើយកន្លែងណាគួបោះបង្គោល ព្រោះការកាយព្រំរបស់ក្រុមហ៊ុនតាមរបាយការណ៍ថាមានជំរៅជ្រៅ ដែលធ្វើឱ្យបាត់បង់ទឹកសំរាប់ធ្វើកសិកម្មរបស់ប្រជាជនហើយបើឈូសទេកាត់ចំផ្លូវនោះត្រូវរៀបចំដាក់លូឱ្យពួកគាត់វិញ មិនអាចកាយផ្តាច់ផ្លូវរបស់ ពួកគាត់នោះទេ។

ចុងក្រោយឯកឧត្តមគណៈអធិបតីបានថ្លែងអំណរគុណ និងជូនពរដល់សមាជិកនៃអង្គពិធី ពិសេសក្រុមការងារ GCF ដែលខិតខំប្រឹងប្រែងឆ្លៀតឱកាសចំណាយពេលវេលាចូលរួមធ្វើបទបង្ហាញនាពេលនេះ ឱ្យជួបតែពុទ្ធិពរទាំងប្រាំប្រការ និងប្រកាសបិទអង្គពិធីនាពេលនេះ ។

កិច្ចប្រជុំពិភាក្សានេះ បានចប់សព្វគ្រប់ដោយជោគជ័យនៅវេលាម៉ោងដប់មួយ និងហាសិបនាទី នាថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ ស្និទស្នាល និងយោគយល់គ្នាក្រៃលែង ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩

អ្នកធ្វើកំណត់ហេតុ

ហត្ថលេខា

**អ៊ុន ចាន់ណារ៉ូ**

Draft